នៅចំពោះមុខការិយាល័យសហចៅក្រមស៊ើបអង្កេត
អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស
ដាក់ទៅ: សហចៅក្រមស៊ើបអង្កេត
ថ្ងៃដាក់: ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០០៩
ភាគីអ្នកដាក់: សហមេធាវីរបស់លោក អៀង សារី
ភាសាដើម: អង់គ្លេស
ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ឯកសារទទួល
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/date de reception): 21 / 05 / 2009
ម៉ោង (Time/Heure): 15:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: C.A. Ly

សម្ងាត់
CONFIDENTIAL
CONFIDENTIEL
26/05/2009

សាធារណៈ
PUBLIC
18/12/2009

INVESTIGATING JUDGES GREFFIER

## សំណើសុំអោយបំពេញកិច្ចស៊ើបសួរលើកទីបី របស់លោក អៀង សារី

**អ្នកដាក់ឯកសារ៖**
**សហមេធាវីរបស់លោក អៀង សារី**
លោក អាង ឧត្តម
លោក Michael G. KARNAVAS

**អ្នកទទួលឯកសារ៖**
**សហចៅក្រមស៊ើបអង្កេត**
ចៅក្រម យូ ប៊ុនឡេង
ចៅក្រម Marcel LEMONDE

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 18 / 12 / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

លោក អៀង សារី តាមរយៈសហមេធាវីរបស់គាត់ "មេធាវីការពារក្តី") អនុលោមតាមវិធាន ៥៥(១០) នៃវិធានផ្ទៃក្នុង ("វិធាន") របស់ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក")តទៅនេះសូមដាក់នូវជូននូវ*សំណើសុំអោយបំពេញកិច្ចស៊ើបសួរលើកទីបី* នេះទៅការិយាល័យសហចៅក្រមស៊ើបអង្កេត ("ក.ស.ច.ស")។ សំណើនេះគឺដើម្បីដាក់បញ្ចូលទៅក្នុងសំណុំរឿងនូវ ព័ត៌មានទាក់ទងនឹងច្បាប់ជាធរមាន យុទ្ធសាស្រ្ត និង នីតិវិធីនៃកិច្ចស៊ើបសួររបស់ ក.ស.ច.ស ។ ក្នុងសំណុំរឿងមិនបានឆ្លុះបញ្ចាំងអោយបានច្បាស់លាស់អំពីច្បាប់ យុទ្ធសាស្រ្ត និងវិធីសាស្រ្តដែលកំពុងត្រូវបានប្រើប្រាស់ដោយ សហចៅក្រមស៊ើបអង្កេត ដើម្បីធ្វើការស៊ើបសួរ។ ម្យ៉ាងវិញទៀត វាមិនមានអ្វីជាតឹកតាងថាតើ វាមានស្រាប់នូវប្រព័ន្ធនេះដែរឬទេ ហើយបើសិនជាមានថាតើ ប្រព័ន្ធនេះត្រូវបានគេធ្វើតាមដោយហ្មត់ចត់ដោយអ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស ដែរឬទេក្នុងពេលស្រាវជ្រាវរកភស្តុតាងដោះបន្ទុក ។ ការបាត់បង់ព័ត៌មាននេះជះឥទ្ធិពលដោយផ្ទាល់ទៅលើថា តើសហចៅក្រមស៊ើបអង្កេតបានវាយតម្លៃលើការសន្និដ្ឋានលើអង្គហេតុនោះយ៉ាងដូម្តេច ។ ហេតុដូច្នេះ វាចូលទៅក្នុងយុត្តាធិការដោយផ្ទាល់របស់ ក.ស.ច.ស ដើម្បី"ចាត់វិធានការស៊ើបសួរដែលនាំទៅរកការបង្ហាញការពិត[1]" ទាក់ទងទៅនឹងអង្គហេតុដែលមានរៀបរាប់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរ[2] ("ដីកាសុំស៊ើបសួរ") របស់ការិយាល័យសហព្រះរាជអាជ្ញា ("ក.ស.ព")។

## ១. សេចក្តីផ្តើម

១. នៅក្នុងប្រព័ន្ធច្បាប់ស៊ីវិលឡូ (Civil Law System) ដែលមានចៅក្រមស៊ើបអង្កេត តួនាទីរបស់ចៅក្រមនេះគឺធ្វើការស៊ើបសួរដោយឯករាជ្យដើម្បីរកការពិត ។ ចៅក្រមនេះមានភារកិច្ចស្របទៅជាមួយគ្នា ដើម្បីធ្វើការស៊ើបសួរស្វែងរកការពិត ដោយស្រាវជ្រាវរក និងប្រមូលនូវរាល់ភស្តុតាងដាក់បន្ទុក និងដោះបន្ទុកទាំងអស់ និង ពិនិត្យនូវរាល់សាក្សីទាំងអស់ដោយឥតរើសអើង (objective) និងដោយឥតលំអៀង[3]។

---

[1] វិធានផ្ទៃក្នុង ៥៥(៥)។

[2] វិធានផ្ទៃក្នុង ៥៥(២)។

[3] ដូចលោកសាស្រ្តាចារ្យ Professor Renee Lettow Lerner ដែលជាសាស្រ្តាចារ្យ/អ្នកជំនាញខាងប្រព័ន្ធច្បាប់អាមេរិចកាំងម្នាក់ ដែលបានមកធ្វើជាសាក្សីចុងចោទស្តីពីនីតិវិធីព្រហ្មទណ្ឌអាមេរិចកាំង នៅសវនាការបទល្មើសឃាតកម្មនៅតុលាការឧក្រិដ្ឋធ្ងន់ធ្ងរ (*Cour d' Assises*) នៅប្រទេសបារាំង បានសង្កេតថា៖ "ចៅក្រមស៊ើបអង្កេតស៊ើបសួរទៅលើសាច់រឿងដែលមានចែងនៅក្នុងសំណើសុំរបស់រដ្ឋអាជ្ញា ដោយស្ថិតនៅក្នុងព្រំដែនទាំងនោះ ចៅក្រមនេះត្រូវបានគេតម្រូវអោយធ្វើការស្វែងរកភស្តុតាងទាំងភស្តុតាងដាក់បន្ទុក និងទាំងភស្តុតាងដោះបន្ទុក។ ចៅក្រមនេះទទួលបន្ទុកធំធេងដោយត្រូវស្វែងរកគ្រប់ការស៊ើបអង្កេតទាំង

២. ស្រដៀងគ្នាដែរ តួនាទីរបស់ ក.ស.ច.ស តាមវិធានផ្ទៃក្នុងគឺបំពេញនូវកិច្ចស៊ើបសួរមួយដែលប្រកបដោយភាពត្រឹមត្រូវ អោយអស់ពីសមត្ថភាព ("វិរិយភាព") និងហ្មត់ចត់ រួមមាន ប្រមូល និងវាយតម្លៃភស្តុតាង ទាក់ទងនឹងការចោទប្រកាន់នានាដែលមានផ្ទុកនៅក្នុង ដីកាសុំស៊ើបសួរ តាមទស្សនៈវិស័យរបស់ ក.ស.ព, របស់មេធាវីការពារក្តី និងរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណី។ វាមានសារៈសំខាន់ខ្លាំងណាស់ ដែលការស៊ើបសួរបែបនេះត្រូវធ្វើឡើងបុគ្គលទាំងឡាយ ដែលមានការទទួលខុសត្រូវក្នុងការបំពេញកិច្ចស៊ើបសួរនោះ ប្រកបដោយភាពឥតលំអៀង ឯករាជភាព និងមានសមត្ថភាព។ ដូច្នេះវាប្រាកដណាស់ថា សហចៅក្រមស៊ើបអង្កេតចាំបាច់ត្រូវបង្កើតនូវប្រព័ន្ធស៊ើបសួរមួយដែលនឹងត្រូវគោរពតាមដោយនគរបាលយុត្តិធម៌ ឬអ្នកស៊ើបអង្កេត អ្នកវិភាគ ("អ្នកស៊ើបអង្កេតរបស់ក.ស.ច.ស") ដែលបំពេញកិច្ចស៊ើបសួរនោះជំនួសអោយសហចៅក្រមស៊ើបអង្កេតនោះ។

៣. ចាប់តាំងពីភស្តុតាងត្រូវបានដាក់បញ្ចូលក្នុងសំណុំរឿងមក វាគ្មានអ្វីច្បាស់លាស់ថាតើ កិច្ចស៊ើបសួរដែលកំពុងត្រូវបានគេធ្វើឡើងនោះមាន ភាពត្រឹមត្រូវ ប្រកបដោយវិរិយភាព និងហ្មត់ចត់ដែរឬទេ។ ការប្រមូលចងក្រងនូវការស្តាប់ចម្លើយរបស់សាក្សី ត្រូវបានដាក់បញ្ចូលក្នុងសំណុំរឿងដោយចិត្តឯងជាញឹកញាប់រាប់ខែបន្ទាប់ពីការស្តាប់ចម្លើយនោះត្រូវបានធ្វើឡើង[4] ជាមួយនឹងការពន្យល់បន្តិចបន្តួច ឬគ្មានតែម្តងថាតើ ការស្តាប់ចម្លើយនោះត្រូវបានគេធ្វើឡើងយ៉ាងដូម្តេចដើម្បីអោយសមស្របទៅនឹងកិច្ចស៊ើបសួរនោះ។ សំណុំរឿងគ្មានផ្ទុកនូវការកត់សម្គាល់ដែលគេអាចស្វែងរកបានថា ភស្តុតាងដោះបន្ទុក

---

អស់ដែលខ្លួនយល់ឃើញថាមានភាពងាយស្រួលក្នុងការស្វែងរកការពិត (*la mainifestation de la verite*)។ សាស្ត្រាចារ្យ Lerner បន្តរៀបរាប់ថា តើយ៉ាងដូម្តេចនៅក្នុងពេលជំនុំជម្រះនៅតុលាការឧក្រិដ្ឋធ្ងន់ធ្ងរ ដែលចៅក្រមបារាំងចាំបាច់ត្រូវយល់ដឹងថា រដ្ឋអាជ្ញា និងនគរបាលនៅ California អាចមាន"ករណីយកិច្ចខ្លះដើម្បីស៊ើបអង្កេតរកភស្តុតាងដោះបន្ទុក យ៉ាងហោចណាស់នៅក្នុងទ្រឹស្តីដែរ ដែលជាទូទៅ អ្នកទាំងនោះធ្វើដូច្នេះគឺដើម្បីធ្វើអោយពួកគេអស់ចិត្តថា ពួកគេចាប់បានចំជនដែលជាជនជាប់ចោទ(ឬជនដែលគេជឿថាជាជនជាប់ចោទ) ហើយអាចដកយកចេញនូវភស្តុតាងរបស់ចុងចោទទៀតផង"។ ម្តងម្កាល សាស្ត្រាចារ្យ Lerner មានអារម្មណ៍ថា ខ្លួនចាំបាច់ត្រូវចង្អុលប្រាប់ដល់ចៅក្រមបារាំងថា វាមិនដូចជានៅក្នុងការស្តាប់យកចម្លើយដែលធ្វើឡើងដោយចៅក្រមស៊ើបអង្កេតនោះទេ អាជ្ញាធរស៊ើបអង្កេតនៅ California មិន"ចាំបាច់ធ្វើកំណត់ត្រានូវរាល់ព័ត៌មានដោះបន្ទុកទាំងអស់ដែលសាក្សីម្នាក់ផ្តល់មកអោយខ្លួននោះទេ"។ ហេតុដូច្នេះហើយការស្តាប់យកចម្លើយធ្វើដោយអ្នកស៊ើបអង្កេតអាមេរិច មិនគួរត្រូវបានយកជាសំអាង ដូចជាការស្តាប់យកចម្លើយធ្វើឡើងដោយចៅក្រមស៊ើបអង្កេតបារាំងនោះទេ។" អត្ថបទរបស់ Renee Lettow Lerner *ចំណុចផ្លូវបំបែកនៃប្រព័ន្ធច្បាប់ពីរ៖ ជនជាតិអាមេរិចត្រូវគេកាត់សេចក្តីពីបទឃាដកម្មនៅតុលាការឧក្រិដ្ឋកម្មធ្ងន់ធ្ងរ* 2001 U. ILL. L. REV. ទំព័រ ៧៩១ និង ៨០២ (ឆ្នាំ ២០០១)។

[4] *សូមមើលរឿងក្តី អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក-កសចស ដីកាចាត់អោយស៊ើបសួរជំនួស "D166" ចុះថ្ងៃទី ១១ កញ្ញា ២០០៨ ហើយទើបតែដាក់បញ្ចូលក្នុងសំណុំរឿងនាថ្ងៃទី ១២ ឧសភា ២០០៩ ។

ត្រូវបានដាក់បញ្ចូលបន្ថែម ឬមានអ្វីជាតឹកតាងបញ្ជាក់ថា ភស្តុតាងដោះបន្ទុកនោះពិតជាត្រូវបានស្វែងរកដោយអ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស មែននោះ។ ក.ស.ច.ស ទំនងជាបានជ្រើសរើសសាក្សីទាំងឡាយ ត្រឹមតែដោយសារ សាក្សីទាំងនោះត្រូវបានរៀបរាប់ឈ្មោះដោយ ក.ស.ព ។ វាគ្មានភស្តុតាងថា ការធ្វើវិភាគឯករាជ្យលើសាក្សីទាំងនេះត្រូវបានធ្វើឡើងដោយ សហចៅក្រមស៊ើបអង្កេតនៅមុនពេលជ្រើសរើសសាក្សីទាំងនោះឡើយ[5]។ ដោយមានបញ្ហាទាំងនេះហើយ ទើបបានជាមានសំណើសុំអោយបំពេញកិច្ចស៊ើបសួរបែបនេះ។

## ២. អង្គហេតុ

៤. កិច្ចស៊ើបសួរទៅលើលោក អៀង សារី ត្រូវបានចាប់ផ្តើមឡើងនៅថ្ងៃទី ១៨ កក្កដា ២០០៧ ជាមួយគ្នានឹងការដាក់ប្តឹងនូវ ដីកាសុំស៊ើបសួរ ដោយ ក.ស.ព[6] ហើយបន្ទាប់មកវាត្រូវបានបំបែកពីសំណុំរឿងប្រឆាំងនឹង កាំងហ្គេចអ៊ាវ "ឌុច" កាលពីថ្ងៃទី ១៩ កញ្ញា ២០០៧[7] ។ លោក អៀង សារី ត្រូវបានចាប់ខ្លួនកាលពីថ្ងៃទី ១២ វិច្ឆិកា ២០០៧[8] ។

៥. ថ្វីបើ ការចោទប្រកាន់នៅក្នុង ដីកាសុំស៊ើបសួរ គឺមានភាពសម្ងាត់ក្តី ក.ស.ព បានអះអាងបញ្ជាក់*ជាសាធារណៈ* ថា ឧក្រិដ្ឋកម្មដែលគេចោទប្រកាន់នៅក្នុង ដីកាសុំស៊ើបសួរ នោះគឺត្រូវ "បានប្រព្រឹត្តឡើងជាផ្នែកមួយនៃផែនការឧក្រិដ្ឋកម្មរួមដែលបង្កើតបាជាប្រព័ន្ធមួយមិនស្របច្បាប់ និងរំលោភលើសិទ្ធិជាមូលដ្ឋានរបស់ប្រជាជនកម្ពុជា ព្រមទាំងការធ្វើទុក្ខបុកម្នេញទៅលើក្រុមគោលដៅផ្សេងៗដែលកំណត់

---

[5] *សូមមើល សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក-កសចស* អត្ថបទដកស្រង់នៃដីកាចាត់អោយស៊ើបសួរជំនួសចុះថ្ងៃទី ១២ កញ្ញា ២០០៨ "D108"។ ដីកាចាត់អោយស៊ើបសួរជំនួសនេះបានត្រឹមតែបញ្ជាក់ថា ត្រូវស្តាប់ចម្លើយសាក្សីជាក់លាក់ ដែលមានឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរ ហើយបន្ទាប់មក "សាក្សីឯទៀតដែលចាំបាច់ដើម្បីស្វែងរកការពិត" ដោយមិនបានណែនាំបន្ថែមទៀតថា តើធ្វើដូចម្តេចដើម្បីលាតត្រដាងបង្ហាញនូវការពិតនេះ។

[6] *រឿងក្តី អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក-កសចស ដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរ ចុះថ្ងៃទី ១៨ កក្កដា ២០០៧។

[7] *រឿងក្តី អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក-កសចស ដីកាបំបែកសំណុំរឿង ចុះថ្ងៃទី ១៩ កញ្ញា ២០០៧ ។

[8] *រឿងក្តី អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក-កសចស ដីកាសម្រេចឃុំខ្លួន ចុះថ្ងៃទី ១២ វិច្ឆិកា ២០០៧។

ទុកជាមុន"[9]។ ក.ស.ព កីបានបញ្ជាក់អះអាងផងដែរថា ដីកាសុំស៊ើបសួរ រួមបញ្ចូលនូវ "អង្គហេតុខុសៗគ្នាចំនួន ២៥ ស្ថានភាពដែលមានជាអាទិ៍៖ ឃាតកម្ម ការធ្វើទារុណកម្ម ការជម្លៀសដោយបង្ខំ ការឃុំឃាំងដោយខុសច្បាប់ ការបង្ខំអោយធ្វើពលកម្ម ព្រមទាំងការធ្វើទុក្ខបុកម្នេញលើសាសនា នយោបាយ និងជនជាតិភាគតិច[10]" សម្រាប់ជនទាំងឡាយដែល ក.ស.ព បានកំណត់ និងបង្ហាញឈ្មោះជនសង្ស័យចំនួន ៥ រូប ដែលគេចោទថាបានប្រព្រឹត្ត បានជួយ បានជំរុញអោយមានបទឧក្រិដ្ឋទាំងនោះ និង/ឬ មានការទទួលខុសត្រូវខ្ពស់ចំពោះឧក្រិដ្ឋកម្មទាំងនោះ[11]។ ក.ស.ព បានផ្តល់អោយ ក.ស.ច.ស នូវ "ឯកសារជាង ១000 ច្បាប់ ដែលផ្សំបានជាង ១៤.000 ទំព័រ រួមទាំងចម្លើយរបស់ភាគីទីបី និង/ឬ កំណត់ត្រាជាលាយលក្ខណ៍អក្សររបស់សាក្សីជាង ៣៥0 នាក់ បញ្ជីសាក្សីសក្តានុពលចំនួន ៤0 នាក់ផ្សេងទៀត ឯកសារសម័យកម្ពុជាប្រជាធិបតេយ្យជាច្រើនម៉ឺនទំព័រ ព្រមទាំងទីតាំងរណ្តៅសាកសពរួមដែលមិនទាន់គាស់កកាយជាង ៤0 រណ្តៅទៀតផង"[12]។

៦. ចាប់តាំងពីការចាប់ផ្តើមកិច្ចស៊ើបសួររួចមក ទាំងធ្វើដោយខ្លួនឯង ឬតាមរយៈអ្នកស៊ើបអង្កេតរបស់ខ្លួន សហចៅក្រមស៊ើបអង្កេត បានធ្វើការសួរយកចម្លើយយ៉ាងហោចណាស់ចំនួន ៤១៥ យោងទៅតាមដីកាចាត់អោយស៊ើបសួរជំនួសចំនួន ១៤ ។ ក.ស.ច.ស ក៏ទទួលបានផងដែរនូវឯកសារនានា និងភស្តុតាងជាខ្សែភាពយន្ត ពីប្រភពផ្សេងៗដែលវាក៏ត្រូវបានដាក់បញ្ចូលទៅក្នុងសំណុំរឿងផងដែរ[13]។

## ៣. សេចក្តីសង្ខេបលើសំណើសុំ

៧. មេធាវីការពារក្តីសូមស្នើដល់ ក.ស.ច.ស សុំអោយដាក់បញ្ចូលបន្ថែមនូវព័ត៌មានដូចតទៅនេះទៅក្នុងសំណុំរឿង៖

---

[9] *សូមមើល* សេចក្តីប្រកាសព័ត៌មាន សេចក្តីថ្លែងការរបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី ១៨ កក្កដា ២00៧ ទំព័រ ៧ ("សេចក្តីប្រកាសរបស់ ក.ស.ព")។

[10] *អត្ថបទយោងខាងលើ* ទំព័រ ៤។

[11] *អត្ថបទយោងខាងលើ* ទំព័រ ៥។

[12] *អត្ថបទយោងខាងលើ* ទំព័រ ៦។

[13] *សូមមើល រឿងក្តី អៀង សារី* សំណុំរឿងលេខ 00២/១៩-0៩-២00៧-អវតក-កសចស, D161/1, របាយការណ៍ស្តីពីការអនុវត្តដីកាចាត់អោយស៊ើបសួរជំនួស ចុះថ្ងៃទី ៤ កុម្ភៈ ២00៩ ដែលបានពន្យល់អំពីឯកសារចំនួន ៥៤ ដែលបានទទួលពីបណ្ណសារដ្ឋានកម្ពុជា។ *សូមមើលរឿងក្តី អៀង សារី* សំណុំរឿងលេខ 00២/១៩-0៩-២00៧-អវតក-កសចស, D43/IV, របាយការណ៍ស្តីពីការអនុវត្តដីកាចាត់អោយស៊ើបសួរជំនួស ចុះថ្ងៃទី ២២ កុម្ភៈ ២00៨ ដែលពន្យល់ពីឯកសារចំនួន ៩៩ (ចម្លើយសារភាពពីមន្ទីរ-ស២១) ដែលត្រូវបានទទួលពីមជ្ឈមណ្ឌលឯកសារកម្ពុជា។

១. ព័ត៌មានទាក់ទងនឹងច្បាប់នីតិវិធីប្រើប្រាស់ដោយ សហចៅក្រមស៊ើបអង្កេត និង អ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស ទៅលើកិច្ចស៊ើបសួរ។

២. ព័ត៌មានទាក់ទងនឹងផែនការ និងយុត្តិសាស្ត្រទាំងមូលនៃកិច្ចស៊ើបសួរ។

៣. ព័ត៌មានស្តីពីគុណវុឌ្ឍិ និង បទពិសោធរបស់អ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស និងនីតិវិធីប្រតិបត្តិការជាមូលដ្ឋានរបស់ពួកគេ។

៤. ព័ត៌មានស្តីពីការប្រមូល និងការវិភាគលើភស្តុតាងដោះបន្ទុកដោយ ក.ស.ច.ស ។ ចំនុចនេះ ក្រសោបបញ្ចូលទាំងព័ត៌មានទាក់ទងនឹងទ្រឹស្តីជម្រើសនៃអង្គហេតុផ្សេងពីអង្គហេតុរៀបរាប់ក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរដែលត្រូវពិចារណាដោយ ក.ស.ច.ស និងព័ត៌មានស្តីពីថាតើ ទ្រឹស្តីជម្រើសទាំងនេះត្រូវបានគេប្រើប្រាស់យ៉ាងដូចម្តេចទៅក្នុងប្រព័ន្ធសម្រាប់កំណត់ ប្រមូល និងការវិភាគភស្តុតាងដោះបន្ទុក។

## ៤. អង្គច្បាប់

### ក. ករណីកិច្ច និងកាតព្វកិច្ចផ្លូវច្បាប់របស់ ក.ស.ច.ស ទាក់ទងនឹងកិច្ចស៊ើបសួរ

#### ១. យុត្តាធិការ និងវិសាលភាពនៃកិច្ចស៊ើបសួរ

៨. សមត្ថកិច្ចរបស់ អ.វ.ត.ក មានចែងក្នុងមាត្រា ២ នៃច្បាប់ដែលបង្កើត អ.វ.ត.ក[14] ។ មាត្រា ៥(១) នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា បានផ្តល់អាណត្តិដល់ ក.ស.ច.ស អោយបំពេញកិច្ចស៊ើបសួរមុនការជំនុំជម្រះសេចក្តីដាច់មុខតែឯង[15] ។ វិសាលភាពនៃការស៊ើបសួររបស់ ក.ស.ច.ស ត្រូវបានកម្រិតដោយវិធាន ៥៥(២) ដោយត្រូវស៊ើបសួរលើ "អង្គហេតុ

[14] *សូមមើល* ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីនូវឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនាអំឡុងពេលនៃកម្ពុជាប្រជាធិបតេយ្យដែលត្រូវបានធ្វើវិសោធនកម្មនិងប្រកាសអោយប្រើដោយព្រះរាជក្រម នស/រកត/១០០៤/០០៦ ចុះថ្ងៃទី ២៧ តុលា ២០០៤ ។ តាមមាត្រា ២ គោលបំណងនៃ អ.វ.ត.ក គឺ "ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់កម្ពុជា ដែលពាក់ព័ន្ធទៅនឹងអំពើឧក្រិដ្ឋ ការរំលោភទៅលើច្បាប់មនុស្សធម៌អន្តរជាតិ និងទម្លាប់អន្តរជាតិ និងការរំលោភទៅលើអនុសញ្ញាអន្តរជាតិដែលប្រទេសកម្ពុជាទទួលស្គាល់ ហើយដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃ ១៧ មេសា ២៩៧៥ ដល់ថ្ងៃ ៦ មករា ១៩៧៩"។

[15] កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី ៦ មិថុនា ២០០៣ មាត្រា ៥(១) ("កិច្ចព្រមព្រៀង")។

ដែលមានចែងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរ និង ដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរបន្ថែម" ។ មេធាវីការពារក្តីត្រូវបានហាមឃាត់មិនឱ្យអនុវត្តកិច្ចស៊ើបសួរដោយខ្លួនឯង និងត្រូវបញ្ជូនសំណើសុំទាំងអស់ទៅកាន់ ក.ស.ច.ស [16] ។ វិធាន ៥៥(៥) បញ្ជាក់អះអាងថា អំណាចទូលំទូលាយដែលកាន់កាប់ដោយ ក.ស.ច.ស គឺត្រូវបញ្ជូនមកតាមរយៈ "ការលាតត្រដាងបង្ហាញការពិត" ទាក់ទងនឹងអង្គហេតុនានាដែលមានរៀបរាប់ក្នុង ដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរ ។

## ២. ករណីយកិច្ចត្រូវបំពេញកិច្ចស៊ើបសួរដោយឥតលំអៀង

៩. ក.ស.ច.ស ត្រូវបានផ្តល់អំណាចអោយបំពេញកិច្ចស៊ើបសួរ ដើម្បីប្រមូលព័ត៌មានឈានទៅដល់ការលាតត្រដាងបង្ហាញការពិត[17]។ វិធាន ៥៥(៥) ដាក់បន្ទុកលើ ក.ស.ច.ស អោយបំពេញកាតព្វកិច្ចដើរតួជាស្ថាប័នយុត្តិធម៌ឥតលំអៀង ដោយប្រមូល និងវាយតម្លៃភស្តុតាង ថាតើ វាជាភស្តុតាងដាក់បន្ទុក ឬដោះបន្ទុកដោយសេចក្តីក្លៀវក្លាស្មើគ្នា[18]។

## ៣. ការផ្ទេរការងារស៊ើបសួរដោយ ក.ស.ច.ស ទៅអ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស

១០. កិច្ចស៊ើបសួរដែលត្រូវបំពេញក្នុងអំឡុងពេលស៊ើបសួររបស់ ក.ស.ច.ស អាចត្រូវបានធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេត ខ្លួនឯងផ្ទាល់ ឬក៏ផ្ទេរអំណាចទៅអោយនគរបាលយុត្តិធម៌ ឬអ្នកស៊ើបអង្កេតដើម្បីបំពេញកិច្ចស៊ើបសួរជួសខ្លួន។ ការផ្ទេរអំណាចនេះត្រូវបានធ្វើឡើងតាមរយៈដីកាចាត់អោយស៊ើប

---

[16] កន្លងមក ក.ស.ច.ស បានបញ្ជាក់អំពីតួនាទីមានកម្រិត របស់គូភាគីទាក់ទងនឹងកិច្ចស៊ើបសួរ របស់ អ.វ.ត.ក៖ "នៅចំពោះមុខតុលាការនេះ អំណាចក្នុងការបំពេញកិច្ចស៊ើបសួរត្រូវបានចាត់តាំងឱ្យទៅសហចៅក្រមស៊ើបអង្កេតតែចំនួន២រូបប៉ុណ្ណោះ មិនមែនភាគីទាំងឡាយណាទេ។ គ្មានបទប្បញ្ញត្តិណាដែលអនុញ្ញាតឱ្យភាគីទាំងឡាយអនុវត្តកិច្ចស៊ើបសួរជំនួសឱ្យសហចៅក្រមស៊ើបអង្កេតឡើយ ខណៈដែលវាអាចជាការពិតក្នុងប្រព័ន្ធនីតិវិធីផ្សេងៗដែរ។ [...] ហេតុនេះសមត្ថភាពរបស់ភាគីទាំងឡាយក្នុងការធ្វើការអន្តរាគមន៍ គឺត្រូវបានកម្រិតត្រឹមតែជាការសាកសួរបឋម ដែលសារៈសំខាន់ចាំបាច់សម្រាប់ការអនុវត្តន៍សិទ្ធិស្នើសុំឱ្យមានកិច្ចស៊ើបសួរប្រកបដោយប្រសិទ្ធភាព" *សំណុំរឿង នួន ជា* ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស អនុស្សារណៈ ក.ស.ច.ស ជូនចំពោះមេធាវីការពារក្តី ថ្ងៃទី១០ ខែមករា ឆ្នាំ២០០៨ ទំព័រទី ២។ (គូសបញ្ជាក់បន្ថែម)។

[17] ចំពោះប្រភេទនៃកិច្ចស៊ើបសួរដែលធ្វើឡើងដោយ ក.ស.ច.ស *សូមមើល រឿងក្តី អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក-កសចស សំណើសុំអោយបំពេញកិច្ចស៊ើបសួរលើកទីមួយ របស់លោក អៀង សារី ចុះថ្ងៃទី ២០ មីនា ២០០៩ កថាខណ្ឌ ២-៨។

[18] វិធាន ៥៥(៥) ចែងនៅក្នុងផ្នែកពាក់ព័ន្ធថា "ក្នុងការដឹកនាំកិច្ចស៊ើបសួរ សហចៅក្រមស៊ើបអង្កេតអាចចាត់វិធានការស៊ើបសួរដែលនាំទៅរកការបង្ហាញការពិត ដោយអនុលោមតាមច្បាប់។ ក្នុងគ្រប់ករណីទាំងអស់ សហចៅក្រមស៊ើបអង្កេតត្រូវដឹកនាំកិច្ចស៊ើបសួរដោយអនាគតិ ទោះបីជាភស្តុតាងដែលនឹងរកបាននោះជាភស្តុតាងដាក់បន្ទុក ឬភស្តុតាងដោះបន្ទុកក៏ដោយ ...។

សួរជំនួស។ នៅទីនេះសហចៅក្រមស៊ើបអង្កេតតម្រូវអោយអ្នកស៊ើបអង្កេតណាម្នាក់មកពីការិយាល័យរបស់ខ្លួន ឬនគរបាលយុត្តិធម៌ ដើម្បីបំពេញកិច្ចស៊ើបសួរតាមវិធាន ៦២(១០) ជំនួសខ្លួន ។ វិធាន ៦២(២) ចែងនៅក្នុងផ្នែកពាក់ព័ន្ធថា ដីកាចាត់អោយស៊ើបសួរជំនួស "មិនត្រូវសរសេរជាទម្រង់ទូទៅទេ តែត្រូវបញ្ជាក់អោយបានច្បាស់ពីប្រភេទនៃកិច្ចដែលត្រូវធ្វើការស៊ើបសួរ និងដែលមានជាប់ពាក់ព័ន្ធដោយផ្ទាល់ជាមួយនឹងបទល្មើសណាមួយ ឬជាមួយបទល្មើសដែលកំពុងស៊ើបសួរ"[19]។

## ៥. សំណើសុំ

### ក. ព័ត៌មានទាក់ទងនឹងច្បាប់នីតិវិធីដែលប្រើប្រាស់ដោយសហចៅក្រមស៊ើបអង្កេត និងអ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស នៅក្នុងការស៊ើបសួរ

១១. ចំពោះសំណុំរឿង វាមិនមានភាពប្រាកដប្រជាថាច្បាប់មួយណាគ្រប់គ្រងការស៊ើបសួរ។ វាមិនច្បាស់លាស់សោះថាតើ អ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស និងសហចៅក្រមស៊ើបអង្កេតខ្លួនឯងកំពុងអនុវត្តតាមនីតិវិធីដែលបង្កើតឡើងក្នុងវិធានផ្ទៃក្នុង ឬដែលបានបង្កើតឡើងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ("ក្រមនីតិវិធី") ។ ថ្វីបើ អង្គបុរេជំនុំជម្រះ បានយល់ឃើញថា វិធានផ្ទៃក្នុងមានអានុភាពខ្ពស់ជាងក្រមនីតិវិធី[20]ក៏ដោយ វាក៏នៅតែមិនច្បាស់លាស់ដដែលថា តើមានរឿងអ្វីកើតឡើងបើសិនជាកិច្ចស៊ើបសួរមួយធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេត ឬដោយអ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស ម្នាក់ស្របនឹងក្រមនីតិវិធី ប៉ុន្តែផ្ទុយនឹងវិធានផ្ទៃក្នុងវិញនោះ។ ជាលទ្ធផល វាក៏នៅតែមិនមានភាពជាក់លាក់ផងដែរ ថាបើសិនជា ក.ស.ច.ស ពិចារណាថា ខ្លួនចង់ជ្រើសយកជាជម្រើសរវាងប្រភពច្បាប់ទាំងពីរ ហើយដរាបណាសកម្មភាពដែលចោទឡើងជាក់លាក់ណាមួយ ធ្វើស្របទៅតាមប្រភពមួយក្នុងចំណោមប្រភពទាំងពីរ វាត្រូវបានគេពិចារណាថាវាត្រឹមត្រូវតាមនីតិវិធី[21]។

---

[19] គូសបញ្ជាក់បន្ថែម។

[20] *រឿងក្តី នួន ជា* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក-កសចស(អបជ០៦) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ នួន ជា ប្រឆាំងនឹងដីកាសម្រេចបដិសេធសំណើសុំមោឃៈភាព ចុះថ្ងៃទី ២៦ សីហា ២០០៨ កថាខណ្ឌ ១៤-១៥។

[21] ឧទាហរណ៍ ដីកាចាត់អោយស៊ើបសួរជំនួសយោងទៅលើបទបញ្ញត្តិនៃវិធានផ្ទៃក្នុង ដូចជាវិធាន ២៨, ៦០ និង ៦២ ប៉ុន្តែមិនបានយោងលើបទបញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌឡើយ សូម្បីតែវាត្រូវបានប្រើប្រាស់ដូចគ្នាជានីតិវិធីរបស់ អ.វ.ត.ក ដែលជាតុលាការកម្ពុជាក៏ដោយ។ *សូមមើល រឿងក្តី អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក-កសចស ដីកាចាត់អោយស៊ើបសួរជំនួស ចុះថ្ងៃទី ២៧ វិច្ឆិកា ២០០៧ "D91"។

១២. កិច្ចស៊ើបសួរត្រូវគោរពទៅតាមបទបញ្ញត្តិនៃក្រមនីតិវិធី ដោយហេតុថា អ.វ.ត.ក គឺជាតុលាការកម្ពុជាមួយ។ ប៉ុន្តែ វាមិនមានភាពជាក់លាក់ថាតើ តាមការពិតវាពិតជាអញ្ចើងមែនឬក៏អត់ ។ តាមក្រមនីតិវិធីនគរបាលយុត្តិធម៌[22]ត្រូវធ្វើកំណត់ហេតុនូវចម្លើយរបស់បុគ្គលណាម្នាក់ ដែលខ្លួនបានសួរយកចម្លើយនៅក្នុងពេលធ្វើការស៊ើបអង្កេតបឋមរបស់ខ្លួន[23]។ ម្យ៉ាងវិញទៀត នៅពេលធ្វើការស៊ើបអង្កេតបឋមនគរបាលយុត្តិធម៌អាចស្តាប់ចម្លើយបុគ្គលគ្រប់រូបដែលត្រូវបានសង្ស័យថា បានចូលរួមក្នុងការប្រព្រឹត្តបទល្មើស។ កំណត់ហេតុនៃការស្តាប់ចម្លើយនេះ[24] ត្រូវតែធ្វើឡើង អមជាមួយនឹងហត្ថលេខា ឬផ្តិតម្រាមដៃដោយបុគ្គលដែលបានឆ្លើយជាសំគាល់នៅលើគ្រប់ទំព័រនៃកំណត់ហេតុ[25]នោះ បន្ថែមទៅនឹងអត្តសញ្ញាណនៃអ្នកសួរចម្លើយ[26]។ ការណ៍នេះធ្វើឡើងលុះត្រាបន្ទាប់ពីជនដែលត្រូវស្តាប់យកចម្លើយបានអាន និងយល់ព្រមលើខ្លឹមសារនៃកំណត់នោះប៉ុណ្ណោះ[27] ។ ការខកខានមិនគោរពនូវវិធាននីតិវិធីនេះ

---

[22] ក្រមនីតិវិធី មាត្រា ៥៦ (បេសកកម្មរបស់នគរបាលយុត្តិធម៌) "នគរបាលយុត្តិធម៌គឺជាជំនួយរបស់អំណាចតុលាការ។ នគរបាលយុត្តិធម៌មានភារកិច្ចធ្វើការត្រួតពិនិត្យបទឧក្រិដ្ឋ បទមជ្ឈឹម បទលហុ កំណត់អត្តសញ្ញាណ និងចាប់ជនល្មើស ព្រមទាំងប្រមូលភស្តុតាង។" *សូមមើលផងដែរ* ក្រមនីតិវិធី មាត្រា ៦០ (មន្ត្រីនគរបាលយុត្តិធម៌) ដែលមានចែងក្នុងផ្នែកទាក់ទងថា "មានគុណសម្បត្តិជាមន្ត្រីនគរបាលយុត្តិធម៌៖ (១) មន្ត្រីនគរបាលជាតិមានឋានន្តរសក្តិចាប់ពីអនុសេនីយត្រីឡើងទៅ ដែលបានបំរើការងារយ៉ាងតិច ២ឆ្នាំ ក្នុងនគរបាលជាតិរួចហើយ ហើយបន្ទាប់ពីបានទទួលសញ្ញាប័ត្រជាន់ខ្ពស់ខាងនគរបាលយុត្តិធម៌។"

[23] ក្រមនីតិវិធី មាត្រា ៨៤ (ភាពខុសគ្នានៃអំណាចរបស់មន្ត្រីនគរបាលយុត្តិធម៌ទៅតាមការស៊ើបអង្កេត)៖ "អំណាចទាំងឡាយដែលផ្តល់អោយមន្ត្រីនគរបាលយុត្តិធម៌ ខុសគ្នាទៅតាមពេលដែលមន្ត្រីនោះបំរើការក្នុងក្រមខណ្ឌនៃការស៊ើបអង្កេតជាក់ស្តែង ឬក្នុងក្របខណ្ឌនៃការស៊ើបអង្កេតបឋម"។

[24] ចំពោះការស្តាប់ចម្លើយដែលធ្វើឡើងនៅក្នុងពេលស៊ើបអង្កេតបទល្មើសជាក់ស្តែង *សូមមើល* ក្រមនីតិវិធី មាត្រា ៩៣ (កំណត់ហេតុលើការស្តាប់ចម្លើយ) និង មាត្រា ៩៤ (បទបញ្ជាអោយចូលខ្លួនក្នុងករណីការស៊ើបអង្កេតបទល្មើសជាក់ស្តែង) និងសម្រាប់ការស៊ើបអង្កេតបឋម *សូមមើល* ក្រមនីតិវិធី មាត្រា ១១៤ (ការបញ្ជាអោយចូលខ្លួន ការស៊ើបអង្កេតបឋម) និងមាត្រា ១១៥ (កំណត់ហេតុស្រង់ចម្លើយ ការស៊ើបអង្កេតបឋម)។

[25] ក្រមនីតិវិធី មាត្រា ៩៣ (កំណត់ហេតុលើការស្តាប់ចម្លើយ) និង មាត្រា១១៥ (កំណត់ហេតុស្រង់ចម្លើយ ការស៊ើបអង្កេតបឋម)។

[26] ក្រមនីតិវិធី មាត្រា ១០៨ (និទ្ទេសដែលត្រូវចុះនៅក្នុងកំណត់ហេតុ) "កំណត់ហេតុដែលធ្វើដោយមន្ត្រីនគរបាលយុត្តិធម៌ត្រូវចុះ៖ ឈ្មោះនិងឋានៈរបស់មន្ត្រីនគរបាលយុត្តិធម៌ អង្គភាពរបស់មន្ត្រីនោះ កាលបរិច្ឆេទ។ ទំព័រនីមួយៗត្រូវចុះហត្ថលេខាដោយមន្ត្រីនគរបាលយុត្តិធម៌។ ពាក្យឆ្លូតលុប និងការយោងត្រូវមានបញ្ជាក់យល់ព្រមដោយមានចុះហត្ថលេខារបស់មន្ត្រីនគរបាលយុត្តិធម៌ នៅរឹមទំព័រ។ កំណត់ហេតុស្តីពីការស្តាប់ចម្លើយ ឬស្តីពីការឃាត់ខ្លួន ត្រូវមានចុះអត្តសញ្ញាណរបស់បុគ្គលពាក់ព័ន្ធ។"

[27] ក្រមនីតិវិធី មាត្រា ៩៣(កំណត់ហេតុលើការស្តាប់ចម្លើយ) និង មាត្រា១១៥ (កំណត់ហេតុស្រង់ចម្លើយ ការស៊ើបអង្កេតបឋម)។

បណ្ដាលអោយការស្ដាប់យកចម្លើយត្រូវទុកជាមោឃៈ[28] ។ វាមិនប្រាកដថាតើ ទម្រង់ទាំងនេះកំពុងត្រូវបានគេប្រើប្រាស់ដែរឬក៏អត់។

១៣. កាតព្វកិច្ចដើម្បីពិពណ៌នាអោយបានជាក់លាក់នូវច្បាប់ សម្រាប់អនុវត្តទៅលើកិច្ចស៊ើបសួរគឺធ្វើអោយលេចច្បាស់ ដោយហេតុថា ការិយាល័យរបស់សហចៅក្រមស៊ើបអង្កេត មានអ្នកស៊ើបអង្កេតពីរក្រុម គឺមួយក្រុមជាជនជាតិខ្មែរ និងមួយក្រុមទៀតជាជនជាតិបរទេស។ ខណៈដែលក្រុមជនជាតិខ្មែរ ដូចជាសមហេតុផលជាងថា នឹងគោរពតាមប្រព័ន្ធដែលកំណត់ដោយក្រមនីតិវិធី ដោយឡែកក្រុមជនបរទេសទំនឹងជាស្វែងរកតាមវិធានផ្ទៃក្នុង។ ដោយខកខានមិនបានធ្វើអោយជ្រះស្រលះអំពីច្បាប់ដែលបញ្ញត្តិអំពីការស៊ើបសួរ ក.ស.ច.ស កំពុងមិនអនុញ្ញាតអោយគូភាគីតាមរឿងនោះជាប់ យល់ និងពិនិត្យឡើងវិញនូវកិច្ចស៊ើបសួរ។

១៤. **អាស្រ័យហេតុនេះ** មេធាវីការពារក្ដីសូមស្នើដោយគោរពដល់ ក.ស.ច.ស សុំដាក់បញ្ចូលបន្ថែមនូវព័ត៌មានដូចខាងក្រោមទៅក្នុងសំណុំរឿង៖

១. ច្បាប់មួយណាដែលកំពុងត្រូវបានប្រើប្រាស់ដោយ ក.ស.ច.ស ទៅលើកិច្ចស៊ើបសួរ។

២. បើសិនជាមានច្បាប់ច្រើនជាងមួយកំពុងត្រូវបានអនុវត្ត តើមានលក្ខណៈវិន្ន័យអ្វីត្រូវបានប្រើប្រាស់នៅក្នុងដំណើរការជ្រើសរើស។

## ខ. ព័ត៌មានទាក់ទងនឹងផែនការ និងយុទ្ធសាស្ត្រទាំងមូលរបស់សហចៅក្រមស៊ើបអង្កេតទៅលើការស៊ើបសួរ

១៥. ការទទួលខុសត្រូវទៅលើការស៊ើបសួរចែករំលែកគ្នារវាងសហចៅក្រមស៊ើបអង្កេតទាំងពីរ ដែលមានម្នាក់ជាសហចៅក្រមស៊ើបអង្កេតខ្មែរ និងម្នាក់ទៀតជាសហចៅក្រមស៊ើបអង្កេតអន្តរជាតិ[29]។ សហចៅក្រមស៊ើបអង្កេតទាំងពីរ ត្រូវតែព្រមព្រៀងគ្នាទៅលើសកម្មភាព ឬសេចក្ដីសម្រេចតាមប្រព័ន្ធដែលបង្កើតឡើងដោយច្បាប់បង្កើតតុលាការ[30]នេះ ហើយហេតុដូច្នេះត្រូវតែធ្វើការងារជាមួយគ្នាដើម្បី

---

[28] ចំពោះការមោឃៈនីតិវិធីការស៊ើបសួរក្នុងករណីបទល្មើសជាក់ស្ដែង *សូមមើល* ក្រមនីតិវិធី មាត្រា ១០៩ (មោឃៈភាពនៃការមិនគោរពវិធានបញ្ញត្តិ) និងក្នុងករណីស៊ើបអង្កេតបឋម *សូមមើល* មាត្រា ១១៧ (មោឃៈភាពនៃការមិនគោរពវិធានបញ្ញត្តិ)។

[29] កិច្ចព្រមព្រៀង មាត្រា ៥(១)។

[30] ច្បាប់បង្កើតតុលាការ មាត្រា ២៣ ។

បង្កើតឡើងនូវយុទ្ធសាស្ត្រសម្រាប់ការប្រព្រឹត្តទៅនៃកិច្ចស៊ើបសួរ[31]។ម្យ៉ាងវិញទៀត ដោយសារទំហំ និងភាពស្មុគស្មាញនៃដីកាសុំស៊ើបសួរ វាប្រហែលជាថាការទទួលខុសត្រូវចម្បងរបស់សហចៅក្រមស៊ើបអង្កេត គឺមិនមែនត្រូវបំពេញកិច្ចស៊ើបសួរដោយខ្លួនឯងឡើយ។ ជាមួយគ្នានេះដែរ សហចៅក្រមស៊ើបអង្កេតត្រូវបង្កើតនូវយុទ្ធសាស្ត្រទាំងមូលនៃការស៊ើបសួរ ដូចជាត្រូវធ្វើផែនការ ណែនាំដំណាក់កាលនៃការនៃការស៊ើបសួរ ដែលនឹងត្រូវអនុវត្តដោយអ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស ក្រោមការដឹកនាំរបស់ខ្លួន។ ការអនុវត្តនូវការស៊ើបសួរ*ត្រូវតែ*ធ្វើឡើងនៅក្នុងដែនកំណត់នៃយុទ្ធសាស្ត្រស៊ើបសួរដែលរចនាឡើងដោយសហចៅក្រមស៊ើបអង្កេត។

១៦. សំណុំរឿងមិនបង្ហាញអោយឃើញដោយ*ច្បាស់លាស់ និងមានតម្លាភាព*អំពីយុទ្ធសាស្ត្ររបស់សហចៅក្រមស៊ើបអង្កេតក្នុងការបំពេញកិច្ចស៊ើបសួរឡើយ។ ជនត្រូវចោទទាំងឡាយមិនយល់ដឹងថាតើ សិទ្ធិនានារបស់ខ្លួនកំពុងត្រូវបានការពារដែរឬទេ ដោយសហចៅក្រមស៊ើបអង្កេតដែល*ត្រូវតែ*ដើរតួជាស្ថាប័នឥតលំអៀងមួយនោះ។

១៧. នៅក្នុងប្រព័ន្ធច្បាប់ខំម៉ុនឡូ (common law system) រដ្ឋអាជ្ញាទទួលខុសត្រូវធ្វើការស៊ើបអង្កេត ហើយ វាមិនចាំបាច់តម្រូវអោយធ្វើការស៊ើបអង្កេតជួសមុខអោយមេធាវីការពារក្តីឡើយ។ រដ្ឋអាជ្ញាក្នុងប្រព័ន្ធខំម៉ុនឡូ គឺជាភាគីមួយនៅក្នុងកិច្ចដំណើរការនីតិវិធី ហើយមិនតម្រូវអោយផ្តល់ព័ត៌មានស្តីពីយុទ្ធសាស្ត្រនៃកិច្ចស៊ើបសួររបស់ខ្លួនដល់មេធាវីការពារក្តីឡើយ។ ផ្ទុយទៅវិញ អ.វ.ត.ក គឺយកលំនាំតាមប្រព័ន្ធស៊ីវិលឡូ[32] ដែលមាន ក.ស.ច.ស ជាស្ថាប័នតុលាការមួយ*ដែលតម្រូវ*អោយធ្វើកិច្ចស៊ើបសួរមួយដែលឥតលំអៀងដោយប្រមូលភស្តុតាង និងវាយតម្លៃភស្តុតាងទៅតាមទស្សនាទានរបស់ ក.ស.ព, មេធាវីការពារក្តី និងដើមបណ្តឹងរដ្ឋប្បវេណី។ ជាលទ្ធផល ការស៊ើបសួរដែលធ្វើឡើងដោយ ក.ស.ច.ស ត្រូវមានភាពអព្យាក្រឹត មានតម្លាភាព និងធ្វើអោយគេឃើញភ្លាមៗតាមរយៈការពិនិត្យឡើងលើសំណុំរឿង។

---

[31] *សូមមើល* វិធាន ៧២ ដែលមានចែងអំពីនីតិវិធីដើម្បីដោះស្រាយវិវាទរវាងសហចៅក្រមស៊ើបអង្កេត ។ វិធាន ៧២(៣) អនុញ្ញាតថានៅក្នុងពេលដែលមានការខ្វែងយោបល់គ្នា "គ្មានសកម្មភាពណាមួយដែលពាក់ព័ន្ធទៅការខ្វែងយោបល់គ្នា ត្រូវបានអនុវត្តទេ រហូតដល់មានការព្រមព្រៀងគ្នាមួយត្រូវបានបង្កើតឡើង ឬរយៈពេល ៣០ថ្ងៃបានកន្លងហួស ឬអង្គបុរេជំនុំជម្រះបានទទួលយករឿងខ្វែងយោបល់គ្នាមកជំនុំជម្រះ ហើយបានបញ្ចប់នីតិវិធីដោះស្រាយបញ្ហាខ្វែងយោបល់គ្នានេះ"។

[32] *រឿងក្តី អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក-កសចស ដីកាសម្រេចស្តីពីការរំលោភបំពានលើភាពសម្ងាត់នៃកិច្ចស៊ើបសួរ ចុះថ្ងៃទី ៣ មីនា ២០០៩ កថាខណ្ឌ ១៣ ("ដីកាស្តីពីភាពសម្ងាត់") *សូមមើលផងដែរការកត់សំគាល់ខាងលើ* កំណាត់សំគាល់លេខ ៥។

១៨. នាពេលបច្ចុប្បន្ននេះ ការស៊ើបសួរគឺបិទជិតឈឹងទាំងស្រុងទាក់ទងនឹងយុទ្ធសាស្ត្រនៃការស៊ើបសួរទាំងមូល។ លទ្ធផលនៃដីកាចាត់អោយស៊ើបសួរជំនួសគឺជាធម្មតាត្រូវបានដាក់បញ្ចូលទៅក្នុងសំណុំរឿងស្ទើរតែច្របូលច្របល់គ្នាអមដោយការពន្យល់បន្តិចបន្តួចទៅលើថា ហេតុអ្វីបានជាសាក្សីទាំងនេះត្រូវបានគេស្តាប់យកចម្លើយ និងថាតើមានវាការទាក់ទងគ្នាយ៉ាងដូម្តេចរវាងការស្តាប់ចម្លើយទៅនឹងការចោទប្រកាន់ទាំងឡាយនៅក្នុង ដីកាសុំស៊ើបសួរ[33]។ វាអាចទៅរួចដែលថា ការកិច្ចស៊ើបសួរគឺធ្វើឡើងទៅតាមដំណាក់កាលទាក់ទងនឹងតំបន់ភូមិសាស្ត្រ ឬក៏ថាទាក់ទងនឹងអង្គហេតុជាបញ្ហា វាមិនមានព័ត៌មានទាក់ទងនឹងដំណាក់កាលភូមិសាស្ត្រនេះ ឬក៏រយៈពេលនៃការបញ្ចប់របស់វាសោះ។

១៩. ការដាក់បញ្ចូលបន្ថែមនូវយុទ្ធសាស្ត្រសម្រាប់អនុវត្តការស៊ើបសួរទៅក្នុងសំណុំរឿង នឹងអនុញ្ញាតអោយគូភាគីអាចដាក់សំណើសុំអោយបំពេញកិច្ចស៊ើបសួរ ឬអនុញ្ញាតអោយ ក.ស.ព ដាក់នូវដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរបន្ថែមក្នុងអំឡុងពេលមួយសមរម្យ ឧទាហរណ៍ដូចជា នៅមុនរាល់សាក្សីទាំងអស់ទាក់ទងនឹងប្រធានបទជាក់លាក់មួយត្រូវបានគេស្តាប់យកចម្លើយ។ វាក៏នឹងអនុញ្ញាតផងដែរអោយមានយល់ដឹងជាក់ច្បាស់បន្ថែមទៀតទៅលើការស៊ើបសួរ។

២០. **អាស្រ័យហេតុនេះ** មេធាវីការពារក្តីសូមស្នើដោយគោរពដល់ ក.ស.ច.ស សុំដាក់បញ្ចូលបន្ថែមនូវព័ត៌មានដូចខាងក្រោមទៅក្នុងសំណុំរឿង៖

១. យុទ្ធសាស្ត្រទាំងមូលរបស់ ក.ស.ច.ស ក្នុងការបំពេញកិច្ចស៊ើបសួរ ដំណាក់កាលទាំងឡាយដែលការស៊ើបសួរត្រូវបានបំបែកចេញដោយឡែកពីគ្នា និងកាលបរិច្ឆេទតាមរយៈនេះ ក.ស.ច.ស មានផែនការនឹងបញ្ចប់ដំណាក់កាលទាំងនេះ ហើយ

២. ថាតើ មានទិន្នន័យសុក្រិតទាក់ទងនឹងព័ត៌មានដែលបានស្នើសុំនៅក្នុងចំណុច ១ ខាងលើនេះដែរអត់។

---

[33] *រឿងក្តី អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក-កសចស ដីកាចាត់អោយស៊ើបសួរជំនួស ចុះថ្ងៃទី ២៦ ឧសភា ២០០៨ "D125" ដែលរួមមានការស្តាប់ចម្លើយសាក្សីចំនួន ១៦៧ ចម្លើយ យកពីសាក្សីដែលមកពីគ្រប់ទីកន្លែងក្នុងប្រទេសកម្ពុជា ទាក់ទងនឹងឧក្រិដ្ឋកម្មទាំងឡាយផ្សេងៗគ្នា និង តំបន់ភូមិសាស្ត្រផ្សេងៗគ្នា ដែលគ្របដណ្តប់ដោយដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរ។ *សូមមើលផងដែរ រឿងក្តី អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក-កសចស ដីកាចាត់អោយស៊ើបសួរជំនួស ចុះថ្ងៃទី ១១ កញ្ញា ២០០៨ "D166" ដែលមានសាក្សីចំនួន ១២៤ នាក់ត្រូវបានគេស្តាប់យកចម្លើយទាក់ទងទៅនឹងវិធីសាស្ត្រអាវុធមុខពីររបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត។

### គ. ព័ត៌មានស្តីពីគុណវុឌ្ឍិ និង បទពិសោធរបស់អ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស និងនីតិវិធីប្រតិបត្តិការជាមូលដ្ឋានរបស់ពួកគេ

#### ១. គុណវុឌ្ឍិ និង បទពិសោធរបស់អ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស

២១. អ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស ទំនងជាប្រើប្រាស់ហួសកំរិតនៃអំណាចនៅក្នុងការជ្រើសរើសសាក្សីទាំងឡាយ ដើម្បីធ្វើការស្តាប់ចម្លើយ និងអំណាចទៅលើការប្រើសំនួរសម្រាប់សួរសាក្សីទាំងនោះ[34]។ របាយការណ៍ដែលធ្វើឡើងដោយអ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស ទាក់ទងនឹងសាក្សីដែលពួកគេបានស្តាប់យកចម្លើយអនុលោមទៅតាមដីកាចាត់អោយស៊ើបសួរជំនួស ចង្អុលបង្ហាញពីអំណាចទៅលើការសន្និដ្ឋានលើអង្គហេតុចុងក្រោយរបស់សហចៅក្រមស៊ើបអង្កេត។ នៅក្នុងរបាយការណ៍ទាំងនេះ ការវាយតម្លៃទូលំទូលាយនិងធ្ងន់ធ្ងរត្រូវបានគេធ្វើឡើងទៅលើ ភាពជឿជាក់ និងសារសំខាន់របស់ចម្លើយសាក្សីទាំងនោះដែលអ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស បានស្តាប់យកចម្លើយ[35] ។ វាមិនមានលក្ខណៈច្បាស់លាស់ថា តើសហចៅក្រមស៊ើបអង្កេតពិតជាបានពិនិត្យផ្ទៀងផ្ទាត់លើការវាយតម្លៃទាំងនេះដោយផ្ទាល់ជាមួយនឹងការស្តាប់ចម្លើយ/សាក្សីទាំងនោះដែរឬទេ។ គេអាចចោទសួរដោយស្របច្បាប់ថា តើសហចៅក្រមស៊ើបអង្កេត បានត្រឹមតែពឹងផ្អែកទាំងស្រុងទៅលើការវាយតម្លៃទាំងឡាយធ្វើឡើងដោយអ្នកស៊ើបអង្កេតរបស់ខ្លួនឬ?

២២. ដោយសារអំណាចប្រើប្រាស់ដោយអ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស មេធាវីការពារក្តីបានស្នើសុំពីមុនរួចមកហើយ អំពីព័ត៌មានសាវតាររបស់អ្នកស៊ើបអង្កេត/អ្នកវិភាគ របស់ ក.ស.ច.ស

---

[34] *សូមមើល រឿងក្តី អៀង សារី* សំណុំរឿងលេខ 00២/១៩-0៩-២00៧-អវតក-កសចស ដីកាចាត់អោយស៊ើបសួរជំនួស ចុះថ្ងៃទី ២៦ ឧសភា ២00៨ “D125” ។ តាមដីកាចាត់អោយស៊ើបសួរជំនួស អ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស ត្រូវបានណែនាំអោយធ្វើការស្តាប់ចម្លើយសាក្សីដែលមានឈ្មោះជាក់លាក់ និង “សាក្សីដទៃផ្សេងទៀតដែលឈានទៅដល់រកការពិត”។ នេះថ្លែងថា អ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស អាចជ្រើសរើសសាក្សី និងតាមការពន្លាតន័យគឺត្រូវសួរសំណួរយ៉ាងដែលឈានទៅដល់រកការពិត។

[35] *សូមមើល រឿងក្តី អៀង សារី* សំណុំរឿងលេខ 00២/១៩-0៩-២00៧-អវតក-កសចស របាយការណ៍ស្តីពីការអនុវត្តដីកាចាត់អោយស៊ើបសួរជំនួស ចុះថ្ងៃទី ២៩ មករា ២00៨ “D92/10” ។ អ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស ចំនួនពីរនាក់ដែលបានតាក់តែងនូវរបាយការណ៍នេះ ធ្វើការវាយតម្លៃថា តើសាក្សីមានសមត្ថភាព ឬមានភាពស្ទាក់ស្ទើរ។ ពួកគេក៏បានបង្គាប់អោយសហចៅក្រមស៊ើបអង្កេតអោយចេញដីកាបង្គាប់អោយចូលខ្លួននូវសាក្សីម្នាក់ក្នុងចំណោមសាក្សីដែលមានឈ្មោះ។

ចំនួនពីរនាក់គឺ លោក David Boyle[36] និងលោក Stephen Heder[37]។ ដោយគ្មានបានពន្យល់អ្វីសោះរហូតមកទល់សព្វថ្ងៃនេះ ប្រហែលជាជាង ៣ខែរួចមកហើយបន្ទាប់ពីសំណើសុំព័ត៌មានលោក Heder ត្រូវស្នើសុំរួចមក (*ស្រាវជ្រាវបក្សកុំម្មុយនីស្តកម្ពុជា CPK អស់រយៈពេល ៣០ឆ្នាំ ក្នុងមុខងារជាអ្នកសារព័ត៌មាន, ភ្នាក់ងារស៊ើបការណ៍សំងាត់, អ្នកតស៊ូមតិ សិទ្ធិមនុស្ស, ប្រវត្តិវិទូ, មន្ត្រីអង្គការសហប្រជាជាតិ, អ្នកស្រាវជ្រាវផ្នែកច្បាប់ និង ជាអ្នកវិទ្យាសាស្ត្រផ្នែកនយោបាយ" មុនចូលបំរើការងារជាអ្នកស៊ើបអង្កេតនៅការិយាល័យសហចៅក្រមស៊ើបអង្កេត*)[38] ក.ស.ច.ស មិនទាន់បានធ្វើផ្តល់ព័ត៌មានអស់ទាំងនេះនៅឡើយ។ កង្វះខាតក្នុងការចាត់វិធានការរបស់ ក.ស.ច.ស គឺធ្វើអោយមានការភ្ញាក់ផ្អើលដោយហេតុថា ក.ស.ច.ស បានអះអាងជាសាធារណៈថា សំណើសុំព័ត៌មានលោក Heder មានពាក់ព័ន្ធដល់ខ្លឹមសារនៃការស៊ើបសួរ[39]។

២៣. ថ្វីបើតាមកាតព្វកិច្ចផ្លូវច្បាប់ត្រូវធ្វើការដោយឥតលំអៀង នាអំឡុងពេលស៊ើបសួរក៏ដោយ វានៅតែមានជាលក្ខណៈធម្មជាតិរបស់មនុស្ស ដែលថា អ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស ទាំងអស់អាចស្ថិតនៅក្រោមគំនាបនៃឥទ្ធិពលនយោបាយធ្ងន់ធ្ងរមួយ ពីប្រភពផ្សេងៗគ្នាទាំងខាងផ្នែកជាតិ និងអន្តរជាតិ ដើម្បីស្វែងរកទីតាំង ឬផ្តល់អាទិភាពដល់ភស្តុតាងដាក់បន្ទុកប្រឆាំងនឹងជនត្រូវចោទ ជាជាងស្វែងរក

---

[36] *រឿងក្តី អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក-កសចស សំណើសុំព័ត៌មានទាក់ទងនឹងទំនាស់ផលប្រយោជន៍ជាក់ស្តែង និងទំនាស់ផលប្រយោជន៍ដ៏មានសក្តានុពលនៃមន្ត្រីកិច្ចការច្បាប់ David Boyle ចុះថ្ងៃទី ៤ មីនា ២០០៨ ថ្វីបើ មេធាវីការពារក្តីជឿថា មុខងារជា "មន្ត្រីកិច្ចការច្បាប់" ផ្ទុះបញ្ចាំងច្បាស់លាស់ជាងនូវតួនាទីចម្បងរបស់លោក Boyle នៅក្នុង ក.ស.ច.ស មេធាវីដឹងថាមុខងារផ្លូវការលោក Boyle អាចជា "អ្នកស៊ើបអង្កេត/អ្នកវិភាគ"ក៏ដោយ។ ការចាត់ថ្នាក់នូវមុខតំណែងរបស់លោក Bolye ត្រូវបានទទួលព្រមយកដោយ ក.ស.ច.ស ។ *សូមមើល រឿងក្តី អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក-កសចស លិខិតមានចំណងជើងថា "សំណើសុំព័ត៌មានស្តីពី "ការលំអៀងជាក់ស្តែង និងទំនាស់ផលប្រយោជន៍ទាក់ទងនឹងលោក Heder និងលោក Boyle" ចុះថ្ងៃទី ២៦ ឧសភា ២០០៨"។

[37] *រឿងក្តី អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក-កសចស សំណើសុំព័ត៌មានទាក់ទងនឹងទំនាស់ផលប្រយោជន៍ដ៏មានសក្តានុពល របស់អ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស Stephen Heder ចុះថ្ងៃទី ៣០ មករា ២០០៩ ("សំណើទាក់ទង Heder") ។ មេធាវីការពារក្តីបានស្នើសុំពីមុននូវព័ត៌មានផ្សេងទៀតស្តីពីការងារពីមុនរបស់លោក Heder ដែលពីមុននៅជាមួយ ក.ស.ព ។ *សូមមើល រឿងក្តី អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក-កសចស សំណើសុំព័ត៌មានទាក់ទងនឹងទំនាស់ផលប្រយោជន៍ជាយថាហេតុ ចុះថ្ងៃទី ២៤ មករា ឆ្នាំ ២០០៨។

[38] សំណើទាក់ទង Heder កថាខណ្ឌ ១ (មានបញ្ជាក់បន្ថែម)។

[39] ដីកាស្តីពីភាពសម្ងាត់ កថាខណ្ឌ ១៧ ។ *សូមមើលផងដែរ* សេចក្តីប្រកាសព័ត៌មានរបស់សហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី ៣ មីនា ២០០៩។

ភស្តុតាងដែលអាចដោះបន្ទុកទៅវិញ។ គំនាបសង្កត់នេះប្រហែលជាត្រឹមត្រូវខ្លាំង ដោយសារការបន្តធ្វើអោយភ័យខ្លាចដែលចេះតែបន្តរបស់ខ្មែរក្រហម[40]។

២៤. ការចោទប្រកាន់ពីអំពើពុករលួយ ដែលល្បីសុះសាយខ្លាំងជាសាធារណៈនៅក្នុងផ្នែកការិយាល័យរដ្ឋបាល និងការិយាល័យសហចៅក្រមស៊ើបអង្កេតខ្លួនឯង[41] ក៏ទំនងជាដាក់គំនាបសង្កត់ធ្ងន់ធ្ងរបន្ថែមទៀតទៅតាមប្រភេទផ្សេងគ្នានៃករណីទាំងនោះ មកលើអ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស ។ ដោយគិតទៅដល់សំពាធបែបនេះ អ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស អោយមានចេតនាចេញសេចក្តីសម្រេចដោយមិនត្រឹមត្រូវ ផ្ទុយនឹងផលប្រយោជន៍របស់មេធាវីការពារក្តីដែលជាភាគីមួយដែលលាតត្រដាងនូវបញ្ហាដែលគួរអោយអាម៉ាស់នេះឡើង[42]។ អ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស ខ្លះអាចព្យាយាមធ្វើបន្តធ្វើការស៊ើបសួរនោះក្នុងល្បឿនដែលមិនចាំបាច់ ហើយធ្វើការថ្លែងប្រហែលមិនសមរម្យ ដូច្នេះមិនអើពើនឹងភស្តុតាងដោះបន្ទុកដែលមានសារៈសំខាន់។ ការនេះបានត្រឹមតែបន្សល់ទុកអោយ អ.វ.ត.ក ក្លាយជាស្ថាប័នមួយដែលមានកេរ្តិ៍ឈ្មោះមិនល្អ។

---

[40] នៅក្នុងសវនាការដេញដោលផ្ទាល់មាត់ស្តីពីការឃុំខ្លួនបណ្តោះអាសន្ន ក.ស.ព បានដកស្រង់ចេញពីការស្ទាបស្ទង់មតិមួយថា "ចម្លើយ ៤នាក់ក្នុងចំណោម៥នាក់ បាននិយាយថា គេមានអារម្មណ៍លំបាកចំពោះមេដឹកនាំខ្មែរក្រហមដែលបានប្រព្រឹត្តអំពោះឃោរឃៅ។ ៧០ ភាគរយបាននិយាយថា គេចង់អោយឃើញអ្នកទោសទទួលរងទុក្ខក្នុង ៣.១ គឺថា ១/៣ គេនិយាយថា គេអាចនឹងធ្វើការសងសឹកទៅលើអតីតខ្មែរក្រហម ហើយគេអាចនឹងធ្វើដូច្នោះ បើសិនជាគេមានឱកាសនឹងធ្វើដូច្នោះបាន។" សេចក្តីថ្លែងនេះ ដោយមិនសមរម្យខណៈវាស្ថិតនៅក្នុងអំឡុងពេលនៃសវនាការមួយទៅលើការឃុំខ្លួនបណ្តោះអាសន្ន ចង្អុលបង្ហាញថា មានការគៀបសង្កត់ជាសាធារណៈដែលនៅបន្តមានទៅលើអ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស ដើម្បីចេញដីកាចោទប្រកាន់ប្រឆាំងនឹងជនត្រូវចោទ ហើយអាចនឹងទៅជាប្រយោជន៍ដល់ភស្តុតាងដែលនឹងសម្របសម្រួលអោយធ្វើយ៉ាងដូច្នេះបាន។ *សូមមើល រឿងក្តី អៀង សារី* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក-កសចស(អបជ១៧) ប្រតិចារឹត ថ្ងៃទី ២ មេសា ២០០៩ ទំព័រ ៦៨។

[41] *សូមមើល* ទស្សនាវដ្តី Economist ចេញផ្សាយថ្ងៃទី ២ ខែមេសា ឆ្នាំ២០០៩ ក្រោមចំណងជើងថា៖ តុលាការនេះបើកការជំនុំជម្រះ មានការចោទប្រកាន់ពីអំពើពុករលួយគំរាមកំហែងដល់ភាពជឿរជាក់មកលើតុលាការខ្មែរក្រហម៖ "មានបុគ្គលិកតុលាការនេះចំនួន ៣ នាក់ ដែលបាននិយាយក្នុងលក្ខខណ្ឌសុំមិនបញ្ចេញឈ្មោះ ចោទប្រកាន់លោក ស៊ាន វិសុទ្ធ ដែលជាប្រធានការិយាល័យរដ្ឋបាលនៃតុលាការនេះ ថាបានប្រមូលលុយកាក់ពីបុគ្គលិកកម្ពុជាទាំងឡាយនៅក្នុងការិយាល័យរបស់គាត់ រួមមានទាំងបុគ្គលិកតុលាការ និង<u>បុគ្គលិកជំនួការច្បាប់ជាតិនៅក្នុងនានានៅក្នុងការិយាល័យសហចៅក្រមស៊ើបអង្កេត និងសហព្រះរាជអាជ្ញា</u> [...] ប្រាក់កាសនេះមួយចំនួនគឺក្នុងគោលបំណងសំរាប់អោយ សុខ អាន ដែលជាឧបនាយករដ្ឋមន្ត្រី"។ (មានគូសបញ្ជាក់បន្ថែម) ។

[42] *សូមមើល* អត្ថបទរបស់ Douglas Gillison នៃកាសែត *The Cambodia Daily* ចុះថ្ងៃទី ១២ ឧសភា ២០០៩ ថា "រដ្ឋាភិបាលអះអាងថាមានសំណុំរឿងរបស់បុគ្គលិកអង្គការសហប្រជាជាតិ"ទំព័រ ១ នៅពេលលោក ផៃ ស៊ីផាន អ្នកនាំពាក្យរបស់រដ្ឋាភិបាលអះអាងថាមានសំណុំឯកសាររបស់បុគ្គលិកអង្គការសហប្រជាជាតិនៅ អ.វ.ត.ក ដែលជា"សត្រូវរបស់ អ.វ.ត.ក"។

២៥. លទ្ធភាពរបស់អ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស ដើម្បីអនុវត្តនូវកាតព្វកិច្ចផ្លូវច្បាប់របស់ខ្លួនដើម្បីធ្វើការស៊ើបអង្កេតដោយឥតលំអៀង និងពេញលេញ ខណៈដែលទទួលរងនូវគំនាបសង្កត់ដូចដែលបានពិពណ៌នាខាងលើ គឺពឹងផ្អែកទៅលើទំហំធំប៉ុណ្ណានៃគុណវុឌ្ឍិ និងបទពិសោធន៍ដែលអ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស ទាំងនោះមាន។

២៦. **អាស្រ័យហេតុនេះ** មេធាវីការពារក្តីសូមស្នើដោយគោរពដល់ ក.ស.ច.ស សុំដាក់បញ្ចូលបន្ថែមនូវព័ត៌មានដូចខាងក្រោមទៅក្នុងសំណុំរឿង[43]៖

១. ថាតើ អ្នកស៊ើបអង្កេតណាម្នាក់ធ្លាប់បានបំរើការងារនៅក្នុងស្ថាប័នស៊ើបអង្កេតសំខាន់ណាខ្លះទៀតដូចជា មជ្ឈមណ្ឌលឯកសារកម្ពុជា ការិយាល័យសហព្រះរាជអាជ្ញា មុនពេលមកធ្វើការងារនៅការិយាល័យសហចៅក្រមស៊ើបអង្កេត។

២. បទពិសោធន៍ស៊ើបអង្កេតពីមុនរបស់អ្នកស៊ើបអង្កេតនីមួយៗ នៅមុនពេលមកចូលរួមក្នុងការិយាល័យសហចៅក្រមស៊ើបអង្កេត

៣. ព័ត៌មាន ដែលអាចជះឥទ្ធិពលមកលើភាពឥតលំអៀងរបស់អតីត ឬអ្នកស៊ើបអង្កេតបច្ចុប្បន្នរបស់ ក.ស.ច.ស ដែលព័ត៌មានទាំងនោះ សហចៅក្រមស៊ើបអង្កេតដឹងរឿងនេះដោយខ្លួនឯង ឬក៏ត្រូវបានផ្តល់មកសហចៅក្រមស៊ើបអង្កេតដោយភាគីណាមួយ។

៤. ការបណ្តុះបណ្តាល (ច្បាប់ ឬអ្វីផ្សេងទៀត) ដែលបានផ្តល់ជូនដល់អ្នកស៊ើបអង្កេត។

## ២. នីតិវិធីប្រតិបត្តិការជាមូលដ្ឋានរបស់អ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស

២៧. ចាប់តាំងពីអ្នកស៊ើបអង្កេតទាំងជាតិ និងអន្តរជាតិបំរើការងារអោយ ក.ស.ច.ស ពួកគេមានបទពិសោធ និងសាវតារផ្សេងៗគ្នា។ វាក៏មានន័យមិនច្បាស់ជាក់ស្តែងចំពោះច្បាប់នីតិវិធីដែលត្រូវអនុវត្តចំពោះការស៊ើបសួរ ដោយយោងទៅលើកថាខណ្ឌទី ១១ ដល់ ១៤ នៅទីនេះ។ ដើម្បីបង្ការនូវភាពខុសប្លែកគ្នាកុំអោយបង្កការខូចខាតដល់ការស៊ើបសួរ សហចៅក្រមស៊ើបអង្កេតគួរបានបង្កើតនូវនីតិវិធីប្រតិបត្តិការជាមូលដ្ឋាន (Standard Operation Procedures)សម្រាប់ការអនុវត្តនូវការ

---

[43] ព័ត៌មានដែលបានស្នើសុំអនុវត្តទៅលើ អ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស ទាំងបុគ្គលិកកម្ពុជា ឬ បុគ្គលិកអន្តរជាតិ ដែលបានធ្វើនៅនៅពេលណាមួយក្នុងដំណាក់កាលស៊ើបសួរនៃសំណុំរឿងលេខ ០០២ ទោះថាពួកកំពុងនៅបំរើការងារ ឬក៏ឈប់ នៅការិយាល័យសហចៅក្រមស៊ើបអង្កេត។

ស៊ើបសួរ។ ការបង្កើតនូវនីតិវិធីប្រតិបត្តិការជាមូលដ្ឋានបែបនេះ អាចជួយធានានូវសុច្ចរិតភាពនៃការស៊ើបសួរ ដោយអនុញ្ញាតអោយការស៊ើបសួរត្រូវធ្វើឡើងក្នុងលក្ខណៈស៊ីសង្វាក់គ្នា និងត្រឹមត្រូវ ។

២៨. **អាស្រ័យហេតុនេះ** មេធាវីការពារក្តីសូមស្នើដោយគោរពដល់ ក.ស.ច.ស សុំដាក់បញ្ចូលបន្ថែមនូវព័ត៌មានដូចខាងក្រោមទៅក្នុងសំណុំរឿង៖

១. ថាតើ គ្រប់របាយការណ៍ទាំងអស់ដែលប្រមូលបានដោយ ក.ស.ច.ស ត្រូវដាក់បញ្ចូលក្នុងសំណុំរឿងដែរឬទេ ហើយមានអ្វីកើតឡើងចំពោះរបាយការណ៍ទាំងឡាយដែលមិនត្រូវបានដាក់បញ្ចូលក្នុងសំណុំរឿង។

២. ថាតើ របាយការណ៍ត្រូវបានធ្វើឡើងដោយអ្នកស៊ើបអង្កេត មានរៀបរាប់លំអិត នូវការកត់សម្គាល់បន្ថែមទៀតធ្វើឡើងនៅនឹងទីកន្លែង វិធានការនានារបស់អ្នកស៊ើបអង្កេត និងការប្រគល់នូវរាល់ភស្តុតាងទាំងអស់ដែលប្រមូលបានត្រូវបានធ្វើឡើង ហើយបើដូច្នេះមែនថាតើ វាត្រូវបានដាក់បញ្ចូលទាំងអស់ទៅក្នុងសំណុំរឿងដែរឬទេ។

៣. ថាតើ ភស្តុតាងដែលមិនមែនជាការស្តាប់ចម្លើយរបស់សាក្សីកំពុងត្រូវបានទទួលដែរទេ និងថាតើ វាត្រូវបានដាក់បញ្ចូលទាំងអស់ទៅក្នុងសំណុំរឿងដែរឬទេ។

៤. ថាតើ សុវត្ថិភាពត្រូវបានដាក់អោយអនុវត្តដើម្បីធានាថា ការស៊ើបសួរត្រូវបានធ្វើឡើងក្នុងរបៀបយ៉ាងដូច្នោះ អញ្ចឹងហើយវានឹងមិនរំលោភបំពានសិទ្ធិរបស់ជនសង្ស័យ មិនបរិហារឬគំរាមកំហែងសាក្សី ឬជនរងគ្រោះ និងធានាអោយមានការការពារជាអតិបរិមា និងការថែរក្សាភស្តុតាង។

៥. ថាតើ កំណត់ត្រាត្រូវបានរក្សាទុកនូវរាល់ទូទាត់លើការចំណាយដោយអ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស ទៅលើសាក្សី នៅពេលដែលការទូទាត់ទាំងនេះត្រូវបានធ្វើឡើង និងអ្នកណាជាអ្នកសំរេចទៅលើទំហំដែលបានចំណាយ។

៦. ថាតើ មានវិធីសាស្ត្រស៊ីសង្វាក់គ្នាធ្វើឡើងដោយ ក.ស.ច.ស ដើម្បីសាក្សីដែលដឹងព័ត៌មានពីខាងក្នុងនិង ផ្តល់នូវវិធានការការពារ ឬកិច្ចព្រមព្រៀងពីអភ័យឯកសិទ្ធិ។

៧. ថាតើ មានវិធីសាស្ត្រស៊ីសង្វាក់គ្នាចំពោះសាក្សីចុងចោទដែលមានសក្តានុពលដែលអាចតម្រូវអោយមានវិធានការការពារបន្ថែមទៀត ច្រើនជាងសាក្សីដែលផ្តល់ភស្តុតាងប្រឆាំងនឹងជនជាប់ចោទ។

៨. ថាតើ អ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស បានរក្សាទុកនូវបញ្ជីសំណួរដែលពួកគេបានសួរទៅបុគ្គលដែលពួកគេបានស្តាប់ចម្លើយ។

៩. ថាតើ អ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស បានរក្សាទុកនូវខ្សែចង្វាក់នៃការរក្សាភស្តុតាងដែលប្រមូលបាន និងត្រូវបានដាក់បញ្ចូលក្នុងសំណុំរឿង។

**ឃ. ការស៊ើបសួរទាក់ទិនទៅនឹងការប្រមូល និង វិភាគភស្តុតាងដោះបន្ទុកដោយ ក.ស.ច.ស**

**១. កាតព្វកិច្ចស្វែងរកភស្តុតាងផ្ទុយ**

២៩. អនុលោមតាមវិធានផ្ទៃក្នុង ក.ស.ច.ស មានកាតព្វកិច្ចផ្តួចផ្តើមការស៊ើបសួរស្វែងរកភស្តុតាងដោះបន្ទុកដោយយកចិត្តទុកដាក់។ វិធាន ៥៥(៥) ការប្រើអាជ្ញាបញ្ញា "ត្រូវបំពេញកិច្ចស៊ើបសួររបស់ពួកគេដោយអនាគតិ ទោះបីជាភស្តុតាងដែលនឹងរកបាននោះជាភស្តុតាងដាក់បន្ទុក ឬ ភស្តុតាងដោះបន្ទុកក៏ដោយ"[44] ជំនួសឱ្យ"អាច"ស៊ើបសួរ ដែលបង្ហាញថា ក.ស.ច.ស ពុំមានអំណាចឆន្ទានុសិទ្ធិទាក់ទងនឹងកិច្ចស៊ើបសួរដោយអនាគតិ នោះទេ។ ក.ស.ច.ស ដាច់ខាតមិនអាចតម្កល់ភស្តុតាងដែលគាំទ្រការចោទប្រកាន់របស់ ក.ស.ព អោយនៅខ្ពស់ជាងភស្តុតាងផ្សេងទៀតដែលអាចធ្វើអោយខូចខាតដល់ការចោទប្រកាន់ទាំងនោះឡើយ។ ក.ស.ច.ស ត្រូវតែយកចិត្តដាក់ស្មើៗគ្នាលើការប្រមូល និងវិភាគភស្តុតាង ទាំងភស្តុតាងដាក់បន្ទុក និងភស្តុតាងដោះបន្ទុក។

៣០. នៅពេល ក.ស.ព បានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ស្របតាមវិធាន ៥៣(១) ក.ស.ច.ស បានកាតព្វកិច្ចផ្តួចផ្តើមការស៊ើបសួរ[45] ស្វែងរកអង្គហេតុណាដែលមានចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរតែប៉ុណ្ណោះ[46]។ ជាផលវិបាក ក.ស.ច.ស មានកាតព្វកិច្ចតាមផ្លូវច្បាប់ធ្វើការស៊ើបសួរទៅលើការចោទប្រកាន់ ដោយផ្អែកលើភស្តុតាងដាក់បន្ទុកដែលសន្មត ដែលត្រូវបានស្នើឡើងដោយ ក.ស.ព ស្របតាមវិធាន ៥៣(២) ដើម្បីគាំទ្រដល់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។ ភារកិច្ចស្របគ្នាកើតមានឡើងក្នុងវិធាន ៥៥(៥) ដើម្បីធ្វើការស៊ើបអង្កេតជាមុននូវភស្តុតាង ឬ ទ្រឹស្តីដែលផ្ទុយ ឬធ្វើអោយអន្តរាយដល់ការចោទប្រកាន់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។ ភស្តុតាងដោះបន្ទុកមិនអាចកើតឡើងជាអរូបីបាននោះទេ វាត្រូវតែទាក់ព័ន្ធក្នុងរបៀបណាមួយជាមួយភស្តុតាងដាក់បន្ទុក ឧទាហរណ៍ដូចជា ការបង្ហាញពីភាពគ្មានទោសរបស់ជនជាប់ចោទ ការបន្ធូរបន្ថយទោសរបស់ជនជាប់ចោទ ឬ ការប៉ះពាល់ដល់ភាពអាចជឿទុកចិត្តបាននៃភស្តុតាងដាក់បន្ទុក[47]។ ជាជម្រើស វាអាចជាភស្តុតាងដោះបន្ទុក ដែលក្នុងវាធ្វើអោយប៉ះពាល់ដល់ ការសន្និដ្ឋានលើអង្គហេតុដែលត្រូវបាន

---

[44] បញ្ជាក់បន្ថែម ។

[45] វិធាន ៥៥(១) ។

[46] វិធាន ៥៥(២) ។

[47] សូមមើលវិធាន ៥៣(៤) ដែលផ្តល់និយមន័យនៃភស្តុតាងដោះបន្ទុកនេះ។

សំរេច ឬនឹងត្រូវបានសំរេចដោយ ក.ស.ច.ស ដើម្បីវាយតម្លៃលើភស្តុតាងដែល ក.ស.ច.ស បានប្រមូលឬវាយតម្លៃ ទាក់ទងទៅនឹងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ [48]។

៣១. ការតម្រូវឱ្យ ក.ស.ច.ស ផ្តួចផ្តើមស៊ើបសួរស្វែងរកភស្តុតាងដោះបន្ទុកនេះ គឺស្របតាមប្រព័ន្ធមួយដែលបង្កើតឡើងដោយតុលាការព្រហ្មទណ្ឌអន្តរជាតិ ("ICC")។ ទោះបី ICC ជាតុលាការអន្តរជាតិដែលមិនមែនជាតុលាការក្នុងស្រុកក៏ដោយ ក៏តុលាការនេះជ្រើសយកប្រព័ន្ធមួយដែលមានប្រយោជន៍ដល់អង្គជំនុំជម្រះវិសាមញ្ញនេះ។ លក្ខន្តិកៈនៃ ICC ដាក់កាតព្វកិច្ចយ៉ាងទូលំទូលាយដល់ព្រះរាជអាជ្ញាជាជាងចៅក្រមស៊ើបអង្កេត[49] ដែលមានការទទួលខុសត្រូវស៊ើបអង្កេតស្វែងរកទាំងភស្តុតាងដាក់បន្ទុក និង ភស្តុតាងដោះបន្ទុកស្មើៗភាពគ្នា"[50]។ អង្គជំនុំជម្រះតុលាការកំពូលរបស់ ICC យល់ឃើញថា ភារកិច្ចស្វែងរក និង បង្ហាញព័ត៌មានដោះបន្ទុកនេះ គឺមិនជាប់ពាក់ព័ន្ធជាមួយមេធាវីការពារក្តីនោះទេៈ ដោយផ្អែកលើការយល់ដឹងរបស់ខ្លួនទៅលើសំណុំរឿង ព្រះរាជអាជ្ញាមានភារកិច្ចជាវិជ្ជមាន ស្វែងរកព័ត៌មានដោះបន្ទុកដែលមានប្រយោជន៍ដល់មេធាវីការពារក្តី[51]។ មេធាវីការពារក្តីអាចប្រើសិទ្ធិនៅស្ងៀមដោយមិនទទួលរងផលវិបាកជាអវិជ្ជមានដែលបង្កឡើងពីការអនុវត្តសិទ្ធិរបស់ខ្លួន ក្នុងការពឹងអាស្រ័យលើភារកិច្ចឯករាជ្យរបស់ព្រះរាជអាជ្ញា ដើម្បីស្វែងរក និង បង្ហាញព័ត៌មានដោះបន្ទុក នោះទេ[52]។

៣២. នៅ អ.វ.ត.ក ភារកិច្ចរបស់សហចៅក្រមស៊ើបអង្កេត ក្នុងការផ្តួចផ្តើមស៊ើបសួរស្វែងរកភស្តុតាងដោះបន្ទុកទាំងឡាយ គឺឯករាជ្យចេញពីសិទ្ធិរបស់មេធាវីការពារក្តីក្នុងការស្នើសុំឱ្យបំពេញកិច្ច ស៊ើបសួរជាក់លាក់ក្រោមវិធាន៥៥(១០)។ សំណើសុំបំពេញកិច្ចស៊ើបសួរដែលធ្វើឡើងក្រោមវិធាននេះ គឺមានបំណង

[48] សូមមើលករណី អៀង សារី សំណុំរឿង 002/19-09-2007-អ.វ.ត.ក/ក.ស.ច.ស(អ.ប.ជ១៩) បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត លើសំណើសុំបំពេញកិច្ចស៊ើបសួរទៅលើការចោទប្រកាន់នៃអំពើពុករលួយដែលកំពុងបន្ត និង សំណើសុំពន្លឿនសវនាការដេញដោលផ្ទាល់មាត់ ចុះថ្ងៃទី ៤ ខែ ឧសភា ២០០៩ កថាខណ្ឌ ៣៩-៤០។

[49] មាត្រា ៥៣ នៃលក្ខន្តិកៈ ICC ។

[50] មាត្រា ៥៤(១) នៃលក្ខន្តិកៈ ICC ។

[51] ករណីព្រះរាជអាជ្ញា តទល់ជាមួយ Lubanga, ICC-01/04/06-1433 សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក Lubanga Dyilo ប្រឆាំងនឹងសេចក្តីសម្រេចផ្ទាល់មាត់របស់ជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ១៨ ខែ មករា ២០០៨ កថាខណ្ឌ ៣៦ ។

[52] ករណីព្រះរាជអាជ្ញា តទល់ជាមួយ Lubanga, ICC-01/04/06-1433 ឧបសម្ព័ន្ធ៣ យោបល់ដាច់ដោយឡែក និង ការថ្លែងយោបល់របស់ចៅក្រម Blattmann ដែលភ្ជាប់ជាមួយសេចក្តីសម្រេចលើបញ្ហាបង្ហាញព័ត៌មាន, ការទទួលខុសត្រូវចំពោះវិធានការការពារ និង បញ្ហានីតិវិធីផ្សេងទៀត ចុះថ្ងៃទី ២៤ មេសា ២០០៨ កថាខណ្ឌ 41-44, និង 50 ។

បំពេញបន្ថែមការស៊ើបសួរស្វែងរកភស្តុតាងដោះបន្ទុករបស់ ក.ស.ច.ស មិនមែនជំនួសឱ្យការស៊ើបសួរបែបនោះទេ។ មានមូលហេតុសំខាន់បីសម្រាប់ការបកស្រាយនេះ៖

ក) ការដាក់សំណើសុំបំពេញកិច្ចស៊ើបសួរ គឺជាជម្រើសទាំងស្រុងរបស់មេធាវីការពារក្តី។ ផ្ទុយពីកាតព្វកិច្ចស្តីពីការស៊ើបសួរដោយអនាគតិរបស់ ក.ស.ច.ស តាមរយៈការប្រើពាក្យ "ត្រូវ" នៅក្នុងវិធាន ៥៥(៥) មេធាវីការពារក្តី "អាចស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេតចេញដីកាបែបនេះ ឬ បំពេញកិច្ចស៊ើបសួរបែបនេះ ប្រសិនបើពួកគេយល់ឃើញថាចាំបាច់"[53]។ មេធាវីការពារក្តីពិតជាគ្មានកាតព្វកិច្ច ស្វែងរកភស្តុតាងដោះបន្ទុកនោះទេ[54]។

ខ) ដាក់លក្ខខណ្ឌដល់មេធាវីការពារក្តីឱ្យកំណត់សំនួរនីមួយៗដែលត្រូវសួរ, កំណត់អត្តសញ្ញាណ សាក្សីនីមួយៗដែលត្រូវស្តាប់យកសក្ខីកម្ម ឬ ឯកសារនីមួយៗដែលត្រូវស្វែងរកដើម្បីចំរាញ់ យកព័ត៌មានដោះបន្ទុកដែលនឹងដណ្តើមយកអំណាចស៊ើបសួរផ្តាច់មុខរបស់ ក.ស.ច.ស។ តាមពិតវាមានន័យថា ក.ស.ច.ស នឹងទទួលផលប្រយោជន៍ពីមេធាវីការពារក្តី ដែលមិនអាចបំពេញកិច្ចស៊ើបសួរដោយខ្លួនឯងបានប្រសិនបើ ក.ស.ច.ស មិនទទួលយកបន្ទុកស៊ើបសួរយ៉ាងត្រឹមត្រូវ និង អនាគតិ ដោយខ្លួនឯងនោះ។

គ) ការតម្រូវឱ្យក្រុមការពារក្តីដាក់សំណើសុំបពេញកិច្ចស៊ើបសួរមុនធ្វើការស៊ើបសួរណាមួយដើម្បីស្វែងរកភស្តុតាងដោះបន្ទុកនោះ នឹងរំលោភសិទ្ធិរបស់ជនជាប់ចោទក្នុងការនៅស្ងៀមមិនឆ្លើយ។ រាល់សំណើសុំបំពេញកិច្ចស៊ើបសួរដែលធ្វើឡើងមេធាវីការពារក្តីជួសមុខឱ្យជនជាប់ចោទ បញ្ជាក់ពីការទំនាក់ទំនងរវាងសំណើសុំបំពេញកិច្ចស៊ើបសួរ និង គោលជំហររបស់ជនត្រូវចោទខ្លួនឯង។ ការបង្ខំឱ្យជនត្រូវចោទដាក់សំណើសុំបំពេញកិច្ចស៊ើបសួរ ស្វែងរកភស្តុតាងដោះបន្ទុក ដើម្បីធានាថាភស្តុតាងបែបនេះត្រូវបានបញ្ចូលក្នុង

[53] វិធាន ៥៥(១០) (បញ្ជាក់បន្ថែម)។

[54] សូមកត់សំគាល់ថា ផ្អែកតាមវិធានផ្ទៃក្នុង នៅក្នុងដំណាក់កាលស៊ើបសួរ មេធាវីការពារក្តីពុំមានកាតព្វកិច្ចដាក់សារណាទៅអង្គបុរេជំនុំជម្រះ ដែលខុសពីការអនុវត្តនៅតុលាការព្រហ្មទណ្ឌអន្តរជាតិដែលមេធាវីការពារក្តីមានកាតព្វកិច្ចដាក់សារណា។ សូមមើលវិធាន វិធាន 65ter(F) នៃវិធានស្តីពីនីតិវិធី និង ភស្តុតាងរបស់ ICTY ដែលដាក់កាតព្វកិច្ចលើមេធាវីការពារក្តីដាក់, បន្ទាប់ពីព្រះរាជអាជ្ញាដាក់សារណារបស់ខ្លួនដែលភ្ជាប់ជាមួយបញ្ជីឈ្មោះសាក្សី និង វត្ថុតាងទៅអង្គបុរេជំនុំជម្រះ, "សារណាមុនអង្គសេចក្តីដែលលើកឡើងពីបញ្ហាអង្គហេតុ និងអង្គច្បាប់ និងបញ្ចូលសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរដែលលើកឡើងពី (១) ចរិតលក្ខណៈ នៃការការពាររបស់ជនជាប់ចោទ, (២) បញ្ហាទាក់ទងនឹងការជំទាស់របស់ជនជាប់ចោទទៅលើសារណាមុនអង្គសេចក្តីរបស់ព្រះរាជអាជ្ញា និង(៣) មូលហេតុនានាដែលនាំឱ្យជនជាប់ចោទជំទាស់ បន្ទាប់ពីព្រះរាជអាជ្ញាដាក់សារណារបស់ខ្លួនដែលភ្ជាប់ជាមួយបញ្ជីឈ្មោះសាក្សី និង វត្ថុតាង ទៅអង្គបុរេជំនុំជម្រះ ។

សំណុំរឿង នៅពេលដែលគាត់ជ្រើសរើសអនុវត្តសិទ្ធិនៅស្ងៀមរបស់គាត់ គឺពិតជារំលោភសិទ្ធិនេះយ៉ាងច្បាស់ក្រឡែក។

៣៣. ព័ត៌មាននៅក្នុងសំណុំរឿងមិនច្បាស់លាស់ថាតើ ក.ស.ច.ស បានប្រតិបត្តិភារកិច្ចនេះដោយឯករាជ្យ និង បានផ្តួចផ្តើមស្វែងរកភស្តុតាងដោះបន្ទុក ដោយពិចារណាយ៉ាងប្រុងប្រយ័ត្នលើជម្រើសផ្សេងនៃទ្រឹស្តីនៃការចោទប្រកាន់ និងទ្រឹស្តីនៃព្រឹត្តិការណ៍ ដូចដែលបានពិពណ៌នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ដែរ ឬយ៉ាងណា។ តាមពិត ពុំមានភស្តុតាងនៅក្នុងសំណុំរឿងដែលបញ្ជាក់ថា ក្រុមអ្នកស៊ើបអង្កេតត្រូវផ្តល់នូវសេចក្តីណែនាំណាមួយ ដែលអាចឲ្យពួកគេយល់ និង ពិចារណាទ្រឹស្តីផ្សេង ហើយធ្វើការស៊ើបសួរស្របតាមទ្រឹស្តីនោះ។

៣៤. វិធីសាស្ត្រដែលអនុម័តដោយ ក.ស.ច.ស ត្រូវបានគេយល់ថា ធ្វើឲ្យខូចប្រយោជន៍ដល់មេធាវីការពារក្តីពីកំណើត។ ភស្តុតាង ជាពិសេសសក្ខីកម្ម (បានស្បថ ឬមិនបានស្បថ) ត្រូវតែបានវិភាគយ៉ាងប្រុងប្រយ័ត្នពីគ្រប់ទិដ្ឋភាពទាំងអស់ នៅពេលទទួលបានភស្តុតាងទាំងនោះ។ មានតែការពិនិត្យគ្រប់ទិដ្ឋភាពទាំងអស់របស់ភស្តុតាងជាបន្តបន្ទាប់នោះទេ ទើបអាចធានាថា ភស្តុតាងត្រូវបានត្រួតពិនិត្យដោយអនាគតិ។ នៅកម្រិតអប្បបរិមាមេធាវីការពារក្តីមានសិទ្ធិរំពឹងទុកថា (ការព្យាករណ៍ពីប្រភេទព្រឹត្តិការណ៍ ឬប្រភេទនៃព្រឹត្តិការណ៍ពិតប្រាកដ) របស់ខ្លួន មិនអន់ជាងការយល់ឃើញនៅពេលក្រោយនោះទេៈ វាត្រូវតែឋិតនៅក្នុងរង្វង់ពេលវេលាទាំងអស់ ជាពិសេសក្នុងអំឡុងពេលស្តាប់ចម្លើយសាក្សីលើកដំបូង ទាក់ទងនឹងអារម្មណ៍ និង ព្រឹត្តិការណ៍ភាពភ័យខ្លាចបាក់ស្បាត។ ការស៊ើបសួរដែលពិតជាមិនអើពើដល់លទ្ធភាពផ្សេងៗ នៅពេលរកឃើញ ឬ រកបានមកវិញនូវភស្តុតាង គឺមិនបានជួយអ្វីទាំងអស់ ដែលគ្រាន់តែជាប្រយោជន៍ ដល់ព្រះរាជអាជ្ញាទៅវិញ។

៣៥. មេធាវីការពារក្តីបានដាក់សំណើសុំបំពេញកិច្ចស៊ើបសួរ ដោយបានស្នើនូវជម្រើសផ្សេងៗស្តីពីប្រភេទនៃព្រឹត្តិការណ៍ទាក់ទងនឹងការចោទប្រកាន់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ[55]។ សំណើសុំបំពេញកិច្ចស៊ើបសួរទាំងពីរនេះ គឺបំពេញបន្ថែម ជាជាងជំនួសឲ្យការស៊ើបសួរដោយឯករាជ្យរបស់ ក.ស.ច.ស។

[55] ករណី អៀង សារី សំណុំរឿង 002/19-09-2007-អ.វ.ត.ក/ក.ស.ច.ស, សំណើសុំបំពេញកិច្ចស៊ើបសួរលើកទី១ របស់ អៀង សារី ចុះថ្ងៃទី ២០ មីនា ២០០៨, ករណី អៀង សារី សំណុំរឿង 002/19-09-2007-អ.វ.ត.ក/ក.ស.ច.ស, សំណើសុំបំពេញកិច្ចស៊ើបសួរលើកទី២ របស់ អៀង សារី ចុះថ្ងៃទី ២ មេសា ២០០៨។

៣៦. អាស្រ័យហេតុនេះ មេធាវីការពារសំណូមពរ ក.ស.ច.ស មេត្តាបន្ថែមនូវព័ត៌មានខាងក្រោមទៅក្នុងសំណុំរឿង:

i. ថាតើជម្រើសផ្សេងៗស្តីពីប្រភេទនៃព្រឹត្តិការណ៍ ដូចមានចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ត្រូវបានពិភាក្សាដោយ ក.ស.ច.ស ដែរ ឬយ៉ាណា ។

ii. ថាតើជម្រើសផ្សេងៗស្តីពីប្រភេទនៃព្រឹត្តិការណ៍ទាំងនេះគឺជាអ្វី។

## ២. ព័ត៌មានទាក់ទងនឹងប្រព័ន្ធរបស់ ក .ស.ច.ស សម្រាប់ការកំណត់អត្តសញ្ញាណ, ការប្រមូល និង ការវិភាគភស្តុតាងដោះបន្ទុក

៣៧. ភារកិច្ចស៊ើបសួរដោយអនាគតិរបស់សហចៅក្រមស៊ើបអង្កេត មិនអាចផ្ទេរទៅឲ្យអ្នកស៊ើបអង្កេតនៃ ក.ស.ច.ស បានឡើយ ប្រសិនបើគ្មានប្រព័ន្ធរឹងមាំមួយសម្រាប់កំណត់អត្តសញ្ញាណ និង ប្រមូលភស្តុតាងដោះបន្ទុកនោះ។ សំណុំរឿងខ្វះខាតនូវការចង្អុលបង្ហាញដែលថា ក.ស.ច.ស បានបង្កើតប្រព័ន្ធមួយ ដែលជាប្រព័ន្ធរឹងមាំមួយ។ ត្រូវបានរកឃើញថា សហចៅក្រមស៊ើបអង្កេតខកខានមិនបានបង្កើតប្រព័ន្ធរឹងមាំ និង ត្រឹមត្រូវមួយ ហើយដែលអាចអនុវត្តបានចំពោះអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេត។ ហេតុដូច្នេះ សហចៅក្រមស៊ើបអង្កេតហាក់ដូចជាបានបង្កើតវិធីសាស្ត្របណ្តោះអាសន្នសម្រាប់ការស្វែងរកភស្តុតាងដោះបន្ទុក។

៣៨. សារៈសំខាន់របស់វិធីសាស្ត្រជាប្រព័ន្ធដើម្បីកំណត់, ប្រមូល និង វិភាគភស្តុតាងដោះបន្ទុកបែបនេះ មិនអាចមើលរំលងបានទេ។ វាជាមូលដ្ឋានគ្រឹះសម្រាប់ការស៊ើបសួរដោយយុត្តិធម៌ អនាគតិ និង ប្រកបដោយសមត្ថភាព។ កង្វះខាតនូវប្រព័ន្ធនៃការស៊ើបសួរដែលមានលក្ខណៈស្តង់ដារ នឹងបង្កើនភវនីយភាពដែលថា ភស្តុតាងដោះបន្ទុកក្នុងចំនួនដ៏ច្រើននឹងត្រូវបានបំភ្លេចចោលដោយអ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស ដោយសារតែពួកគេមិនបានគិតគូរដល់ការសួរសំនួរ ដែលអាចបង្កើតភស្តុតាងដោះបន្ទុក ឬក៏ដោយសារពួកគេជ្រើសរើសដោយមានចេតនាមិនសួរសំនួរបែបនេះ តែម្តង។

៣៩. សេចក្តីតម្រូវការបង្កើតប្រព័ន្ធរឹងមាំមួយសម្រាប់ស្វែងរកភស្តុតាងដោះបន្ទុក ត្រូវបានជំរុញឡើងដោយកត្តាខុសៗគ្នាជាច្រើន។ ដោយសារតែមានអ្នកស៊ើបអង្កេតជាតិកម្ពុជា និង អ្នកស៊ើបអង្កេតបរទេស ហេតុដូច្នេះ របៀបស៊ើបសួរ ឧទាហរណ៍ដោយអ្នកស៊ើបអង្កេតជនជាតិអូស្ត្រាលី ឬ អាមេរិកកាំង អាចខុសគ្នាយ៉ាងខ្លាំងពីរបៀបស៊ើបសួររបស់អ្នកស៊ើបអង្កេតកម្ពុជា ទោះបីជាពួកគេមានភារកិច្ចដូចគ្នាក៏ដោយ។ នេះជា ផលវិបាកនៃភាពខុសគ្នាយ៉ាងខ្លាំងរបស់ប្រព័ន្ធច្បាប់ និង ប្រព័ន្ធព្រហ្មទណ្ឌរបស់ពួកគេ។ ភាពខុសគ្នា ក្នុងចំណោមអ្នកស៊ើបអង្កេតបរទេសខ្លួនឯងក៏មានច្រើនដែរ។ ភស្តុតាងដែលអាច

ចាត់ទុកថាជាភស្តុតាងដោះបន្ទុកក្រោមប្រព័ន្ធច្បាប់មួយ ប្រហែលជាមិនអាចចាត់ទុកថាជាភស្តុតាងដោះបន្ទុកក្រោមប្រព័ន្ធច្បាប់មួយផ្សេងទៀត។ ប្រសិនបើគ្មានការធ្វើបមាណីកម្មលើប្រព័ន្ធសម្រាប់ការកំណត់ និង ការរក្សាភស្តុតាងដោះបន្ទុកនេះទេ នោះការប្រមូលភស្តុតាងបែបនេះនឹងមិនអាចទទួលយកបានឡើយ។

៤០. ជាចុងក្រោយ លក្ខណៈធម្មជាតិនៃអ្វីមួយដែលបង្កើតបានជាភស្តុតាងដោះបន្ទុក គឺពិតជាស្មុគស្មាញ ជាពិសេសនៅក្នុងសំណុំរឿងដែលសាំញ៉ាំ ដែលការស៊ើបសួរត្រូវក្តោបក្រសោបទៅលើព្រឹត្តិការណ៍ធំៗជាច្រើន ដែលពាក់ព័ន្ធជាមួយមនុស្សជាច្រើននាក់ និងពេលវេលាដ៏យូរ ដូចដែលបានចោទប្រកាន់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ។ អាស្រ័យហេតុនេះ អ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស មិនត្រូវតែដឹងអំពីការចោទប្រកាន់ទាំងអស់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ និងភស្តុតាងគាំទ្រដល់ការចោទប្រកាន់ មុននឹងធ្វើការសាកសួរយកចម្លើយនោះទេ តែត្រូវតែបានពិចារណាលទ្ធភាពនៃការការពារទាំងអស់ ប្រឆាំងនឹងការចោទប្រកាន់ទាំងនេះ ហើយត្រូវរៀបចំសំនួរទាក់ទងនឹងភស្តុតាងដោះបន្ទុក។ ចំនុចនេះតម្រូវឲ្យអ្នកស៊ើបអង្កេត ក.ស.ច.ស ចងចាំនូវអ្វីដែលអាចជាសំនួរដោះបន្ទុក ហើយបង្វែរសំនួរដែលមាននៅក្នុងចិត្តរបស់ពួកគេ ឲ្យជាសំនួរដែលត្រូវបានទទួលស្គាល់ និងសំនួរដែលត្រូវបានធ្វើបមាណីយកម្ម ដែលត្រូវសួរទៅអ្នកដែលត្រូវសម្ភាសន៏យកចម្លើយ។

៤១. អាស្រ័យដោយហេតុផលដែលបានលើកឡើងនៅទីនេះ ក.ស.ច.ស ត្រូវតែមាននៅនឹងកន្លែងនូវប្រព័ន្ធសម្រាប់ការកំណត់, ការប្រមូល និង វិភាគភស្តុតាងដោះបន្ទុកមួយ ដែលអាចផ្ទៀងផ្ទាត់បាន និង មានតម្លាភាព ហើយបញ្ចូលប្រព័ន្ធនេះទៅក្នុងសំណុំរឿងឲ្យទៅជាទម្រង់មួយដែលអាចវាយតំលៃ និង ប្រើប្រាស់ដោយមេធាវីការពារក្តី។ ដើម្បីសម្រេចបាននូវការងារនេះ ក.ស.ច.ស ត្រូវតែមាននៅនឹងកន្លែងនូវប្រព័ន្ធមួយដែលពន្យល់:(១) តើអ្វីទៅដែល ក.ស.ច.ស ចាត់ទុកថាជាភស្តុតាងដោះបន្ទុក ជាពិសេសដោយការបង្កើតលក្ខណៈវិនិច្ឆ័យ ឬ ប្រភេទជាក់លាក់នៃភស្តុតាងនេះ”[56] (២) តើព័ត៏មាននេះទទួលបានដោយរបៀបណា និង (៣) តើ សហចៅក្រមស៊ើបអង្កេតត្រួតពិនិត្យនគរបាលយុត្តិធម៌ ឬ អ្នកស៊ើបអង្កេត ដែលបំពេញកិច្ចស៊ើបសួរជួសមុខឲ្យពួកគេ ថាបានអនុវត្តតាមប្រព័ន្ធនេះយ៉ាងត្រឹមត្រូវដោយរបៀបណា។

---

[56] សូមមើល *ករណីព្រះរាជអាជ្ញា តទល់ជាមួយ Katanga និង Ngudjolo* Réplique du Bureau du Procureur aux Réponses de la Défense sur la « Réponse de l'Accusation au Paragraphe 8 de l'*Ordonnance [*du 10 décembre 2008*] enjoignant aux participants et au Greffe de déposer des documents complémentaires* », ចុះថ្ងៃទី ៩ កុម្ភៈ ២០០៩ កថាខណ្ឌ ១០ ។

៤២. អាស្រ័យហេតុនេះ មេធាវីការពារសូមស្នើដោយក្តីគោរពឱ្យ ក.ស.ច.ស បន្ថែមនូវព័ត៌មានខាងក្រោមចូលទៅក្នុងសំណុំរឿង:

i. ថាតើសហចៅក្រមស៊ើបអង្កេត បានបង្កើតប្រព័ន្ធរឹងមាំមួយសម្រាប់ការកំណត់ ការប្រមូល និង ការវិភាគភស្តុតាងដោះបន្ទុកក្នុងអំឡុងពេលស៊ើបសួរ ដែរឬយ៉ាងណា។

ii. ថាតើសហចៅក្រមស៊ើបអង្កេតបានត្រួតពិនិត្យមើលទេថា ប្រព័ន្ធនេះត្រូវបានអនុវត្តដោយអ្នកស៊ើបអង្កេតទាំងអស់ ដែលទទួលខុសត្រូវក្នុងការអនុវត្តកិច្ចស៊ើបសួរតាមរយៈដីកាចាត់ឱ្យស៊ើបជំនួស។

## VI. ការស្វែងរកដំណោះស្រាយ

អាស្រ័យដោយហេតុផលទាំងអស់ដូចមានបញ្ជាក់ជូននៅនេះ មេធាវីការពារសូមស្នើដោយក្តីគោរពសុំឱ្យ ក.ស.ច.ស ផ្តល់ព័ត៌មានដែលបានស្នើសុំនៅកថាខណ្ឌ ១៤, ២០, ២៦, ២៨, ៣៦ និង ៤២ នៃសំណើលើកទី៣សុំបំពេញកិច្ចស៊ើបសួរនេះ ។

សូមលោកសហចៅក្រមទទួលយកសំណើសុំនេះដោយក្តីគោរព។

ធ្វើនៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី**២១** ខែ**ឧសភា** ឆ្នាំ **២០០៩**

**អាង ឧត្តម** Michael G. KARNAVAS

សហមេធាវីរបស់លោក **អៀង សារី**